D25174
(DC-Cam)

# មជ្ឈមណ្ឌលឯកសារកម្ពុជា

## សម្ភាសន៍ជាមួយ ភោគ ខន នៅភូមិអន្ទង់សាន ឃុំព្រែកស្ដី ស្រុកកោះធំ ខេត្តកណ្ដាល ថ្ងៃទី១៣ ខែសីហា ឆ្នាំ២០០២

ថ្វី: គាត់មកជាមួយពួកខ្ញុំដែរ គាត់មកពីកាណាកា គាត់អរគុណមីងច្រើន ហើយចាត់ទុកមីងថាជាមនុស្សម្នាក់មានសំណាងលើមនុស្សច្រើននាក់ដែលគាត់បានចុះមក កាន់បញ្ជីចុះមក ហើយអត់បានជួប ហីមានតែមីងដែលគាត់ជួប ។

ថ្វី: មីងឆ្នាំនេះមីងអាយុប៉ុន្មាន?

ខន: ខ្ញុំអាយុ៤៧ ។

ថ្វី: មីងកាលហ្នឹងពេលដែលខ្មែរក្រហមចូល មីងកើតជានៅឯណា រស់នៅឯណា?

ខន: កាលចូលហីអន្លាល...?

ថ្វី: កាលដែលខ្មែរក្រហមចូលស្រុកយើងណា?

ខន: ហ្នុងនៅឯស្រុកណុះហ្នឹង ។

ថ្វី: នៅស្រុកណា?

ខន: នៅស្រុកក្រាំងយោ ស្អាង ក្រាំងយោ ។

ថ្វី: មីងមានបានទៅរៀននៅឯណាទេ?

ខន: ខ្ញុំមិនដែរទេ ហ្ហូ! រៀនបានតិចតួចដែរ ។

ថ្វី: មីងអានបានទេ...អានអីបានទេ?

ខន: អានបាន ។

ថ្វី: មីងកាលហ្នុងខ្មែរក្រហមចូលមក មីងអាយុប៉ុន្មាន ហើយចូលធ្វើអាយុប៉ុន្មាន?

ខន: ខ្ញុំវាអត់នឹកឃើញអាយុហ្នុងណា អត់ចាំរឿងអាយុហ្នុងប៉ុណ្ណាអត់ដឹង ។

ថ្វី: កាលហ្នឹងមីងរៀនថ្នាក់ទីប៉ុន្មានហើយ?

ខន: ខ្ញុំនិយាយឥឡូវបើក្មេងឥឡូវរៀនថ្នាក់ទី ពីសង្គមថ្នាក់ទី១០ បើយើងឥឡូវគេថាទី២អីចឹងទៅណា ។

ទ្រី:	មីងកាលហ្នឹងខ្មែរក្រហមចូលមកភូមិមីងនៅក្រាំងយៅនៅឆ្នាំណា?

ខនៈ	ខ្ញុំអត់ដឹងរឿងឆ្នាំហ្នឹងណា អត់ដឹងចាប់អារម្មណ៍ហ្នឹងណា ព្រោះអត់យកចិត្តទុកដាក់និយាយឲ្យចំអត់យកចិត្តទុកដាក់ម៉ង ។

ទ្រី:	មីងកាលហ្នុងមានទម្លាក់គ្រាប់បែកនៅភូមិហ្នឹងទេ?

ខនៈ	កាលពី?

ទ្រី:	មុនខ្មែរក្រហមចូលណា?

ខនៈ	ហ្នឹងសម័យកាលអាមេរិកវ៉ៃហ្នុង?

ទ្រី:	បាទ!

ខនៈ	អូ! អីមិនទម្លាក់ ។

ទ្រី:	ទម្លាក់របៀបម៉េច?

ខនៈ	ហ្ហូ! ទម្លាក់ខ្លះថាដូចធុងសាំងដូចដ៏រអីចឹងវាឆេះណា ទម្លាក់មកអីចឹង អាខ្លះគ្រាប់បែកផ្ទុះអីចឹងទៅ ខ្លះឃើញទម្លាក់ដូចធុងសាំងអីចឹងយើងប៉ុណ្ណឹង អីចឹង ។

ទ្រី:	មីងកាលហ្នឹងមានអារម្មណ៍ម៉េចដែរពេលទម្លាក់គ្រាប់បែកនៅភូមិមីង?

ខនៈ	ភ័យ មានអារម្មណ៍ថាខ្លាចប៉ុណ្ណឹង ។

ទ្រី:	អ្នកណាគេអ្នកទម្លាក់មីង?

ខនៈ	ដឹងអី បើអត់ដឹង ដឹងតែកប៉ាល់ហោះ លើងមេឃហ្នុងដឹងអាណាអ្នកទម្លាក់ អត់ដឹងហ្នឹងហើយ អត់ដឹង នៅក្មេងហ្នឹងដឹងតែភ័យខ្លាចតែប៉ុណ្ណឹង ។

ទ្រី:	មីងកាលហ្នុងមានទាហានប៉ុន្មានក្រុម ប៉ុន្មានពួកនៅក្នុងភូមិយើងបានគេទម្លាក់គ្រាប់បែក?

ខនៈ	អត់មានទេ អត់មានប៉ុនចេះតែឃើញទម្លាក់អីចឹងម៉ងរឿងទាហានមកនៅហ្នឹងទីតាំងវ៉ៃហ្នឹងគ្មានទេ ។

ទ្រី:	ចុះពេលដែលខ្មែរក្រហមចូលមកភូមិមីងដំបូងយើងមានជីវភាពម៉េចដែលបានធូរស្រាលជាងមុន ឬក៏ម៉េច ពេលដេលខ្មែរក្រហមចូល?

ខនៈ	តាំងពីខ្មែរក្រហមដូច ធ្វើស្រែស្រូវអីជាធម្មតាអីចឹងទៅណា ។

ទ្រី:	អីចឹងអត់មានផ្លាស់ប្តូរមុខមាត់ជីវភាពធូរធារអីទេ?

ខនៈ	ចាំ! ព្រោះអីខ្ញុំវានៅក្មេង ខ្ញុំបន្ទុកលើម្តាយឪពុកអីចឹង ម្លោះហើយអត់ដឹងអីទេ បានខ្ញុំប្រាប់ថាអត់ដឹងហ្នឹងណា ។

ទ្រីៈ ម៉េចបានមីងចូលខ្មែរក្រហមតាមរបៀបណា កាលហ្នឹងដំបូង?

ខនៈ ចូលហ្នុងដូចថា បើយើងមិនចូលធ្វើអាហ្នឹងយើងមិនទៅកងចល័ត មិនធ្លាប់ឮដែរសម័យហ្នុងនោះ ។

ទ្រីៈ បាទ!

ខនៈ ហ្នុងហើយ យើងទៅធ្វើកងចល័តលើកដី វែកដីអីចឹងណា ហីបើយើងចូលមកមុនគេអីចឹង អាហ្នឹងវាអត់នៅតឹងអីចឹងពេកណា អត់នៅធ្វើកងចល័តកងអី អីចេះ ។

ទ្រីៈ អីចឹងពេលដែលមីងចូលខាងបដិវត្តហ្នុងទៅយើងមិនបាច់ចាំធ្វើការក្នុងក្រុមចល័តទេអីចឹង?

ខនៈ ចា៎! អត់ទេ អាហ្នុងគេធ្វើគ្នាម្ដុំ មន្ទីរក្រសួងអីចឹងទៅណា គ្រាន់តែធ្វើស្រូវនិយាយរួមជាមួយគេ ។

ទ្រីៈ អីចឹងពេលដែលយើងធ្វើការនៅក្នុងក្រសួងវារាងស្រាលជាងដែរ?

ខនៈ ធ្វើស្រូវរួមហូបជាមួយគ្នាហ្នឹង ដាំពោតដាំស្រូវអីចឹង ។

ទ្រីៈ ស្រាលជាង?

ខនៈ ចា៎! ហ្នឹងខ្ញុំនៅទំនេរធ្វើអីចឹង ។

ទ្រីៈ អីចឹងមីងចូលក្រសួងមន្ទីការងារធ្វើម៉េចខ្លះ?

ខនៈ ធ្វើស្រូវដាំពោត ជីកប្រឡាយ ។

ទ្រីៈ អីចឹងពេលមុនឆ្នាំ៧៥មីងធ្វើអាហ្នឹងដែរ ឬមួយក៏ក្រោយឆ្នាំ៧៥បានធ្វើ?

ខនៈ ធ្វើម៉េច អើលន់ ណុលវៃជាមួយអាមេរិកហ្នឹង ហីនឹងខ្មែរក្រហមវៃគ្នាហ្នឹង ហ្នឹងចូលមកគេធ្វើស្រែអីចឹងម៉ង ។

ទ្រីៈ ហីដល់ក្រោយ៧៥ធ្វើអាហ្នឹងដែរ ឬក៏?

ខនៈ អាដែងពេលវៃហើយបាន រំដោះបានភ្នំពេញហើយណោះ?

ទ្រីៈ បាទ!

ខនៈ រំដោះភ្នំពេញអាហ្នឹងមកនៅភ្នំពេញ ដូចខ្ញុំប្រាប់កសាងគេធ្វើរោងចក្រសាជាថ្មីអីចឹង ធ្វើអីចឹង ។

ទ្រីៈ កាលហ្នឹងអ្នកណាគេអ្នកហៅមីងឲ្យចូលធ្វើបដិវត្ត?

ខនៈ ខ្ញុំថាតាគ្រុយៗហ្នឹង ។

ទ្រីៈ អ្នកណាគេប្រធានឃុំឬ?

ខនៈ ចា៎!

ទ្រីៈ ប្រុស ឬស្រី?

ខនៈ ប្រុស ។

ទ្រីៈ គាត់មនុស្សល្អដែរទេ?

ខនៈ ចា៎! គាត់មានអីគាត់មានដែរ គាត់ស្លាប់បាត់ហើយ ។

ទ្រីៈ គាត់ប្រាប់យើងយ៉ាងម៉េចទៅដើម្បីឲ្យយើងចូលខ្មែរក្រហមហ្នឹង?

ខនៈ គាត់គ្រាន់តែថាអីចេះឥឡូវ ចូលធ្វើនេះហ្នឹងគេទៅឬ ចូលធ្វើបដិវត្តន៍គេទៅ យើងទៅណុះក៏ធ្វើការងារប្រមូលផ្តុំដូចតែគ្នាដែរ ហ្នឹងគេនិយាយតែប៉ុណ្ណឹង ថាអីចឹង ។

ទ្រីៈ អត់មាននិយាយប្រាប់ថា យើងចូលដើម្បីជួយសង្គ្រោមប្រជាជនយើង ឬក៏យើងធ្វើដើម្បីបម្រើមនុស្សអី ។

ខនៈ ចា៎! អត់ទេគ្រាន់តែនិយាយប៉ុណ្ណឹង ។

ទ្រីៈ ពេលដែលពួកខ្មែរក្រហមចូលមកដំបូងគឺថាពួកហ្នឹងជួយ.....ល្អច្រើនដែរឬម៉េច?

ខនៈ អត់ដឹង! ដូចអត់ដឹង អត់ចាប់អារម្មណ៍ ចា៎! ។

ទ្រីៈ កាលហ្នឹងមីងមានបានរៀនវគ្គនយោបាយ សិក្សានយោបាយអប់រំអី?

ខនៈ អើ! គេចេះតែបង្រៀនដូចថា ម៉ាថ្ងៃ២ថ្ងៃអីចឹងម្តងម៉ាកាលហ្នឹង ។

ទ្រីៈ មុន៧៥ណា?

ខនៈ ក្នុងរបបលន់ ណុលហ្នឹងណា ។

ទ្រីៈ បាទ! ពេលខ្មែរក្រហមហ្នឹង?

ខនៈ អត់មានរៀន ។

ទ្រីៈ កាលហ្នឹងមីងមានអារម្មណ៍ដែរជាមួយពួកអ្នកមាន ជាមួយពួកសក្តិភូមិអីណា?

ខនៈ ខ្ញុំអត់មានអារម្មណ៍ថាម៉េចទេ រឿងអ្នកមានអ្នកក្រកាលហ្នឹង ។

ទ្រីៈ ចុះជាមួយពួកចក្រពត្តិនិយមជាមួយពួកអាមេរិកកាំងអីម៉េច គេប្រាប់យើងថាម៉េច?

ខនៈ អត់មានរបាប់ថាម៉េចទេ! គ្រាន់តែដឹងថាវាទម្លាក់គ្រាប់បែកអីចឹងខ្លាចនាំគ្នារត់ទៅ ហើយបើយើងចូលមកធ្វើការងារ អ៊ី! រស់ជាមួយអីចឹងដូចថាវាជៀសពីរើសមកកងចល័តជាមួយគ្នាយើងចូលផុតហើយផុតទៅ ធ្វើការងាររួមតែប៉ុណ្ណឹង ដឹងតែអីចឹងម៉ងរឿងម៉េចមិនដឹង ។

ទ្រី: មីងចង់និយាយថាការងារដូចគ្នាហ្នឹង ដូចគ្នានិងស៊ីការងារហ្នុង?

ខន: ដូចគ្នាដូចថាយើងនៅឯភូមិ ក៏ធ្វើការងាររួម ហូបបាយរួមអីចឹងឬ ចាំ! ដល់យើងមកអគ្គភាពអីចឹងទៅ ដូចថាវាធូរគ្រន់អីចេះ យើងមកអគ្គភាពធ្វើការងារក្នុងអគ្គភាពឈានមុខមួយអីចឹងក្នុងមួយគ្រួសារមានកូនមកមួយដូចថាវាធូរក្នុងគ្រួសារនៅក្រោយម៉ាប៉ែកដែរដូចថាមានអ៊ីទៅគេអាចយល់យោគឃើញអ្នកទៅមួយណាខ្ញុំចង់និយាយអីចឹង ។

ទ្រី: អីចឹងពេលដែលមីង មុនឆ្នាំ៧៥ពេលដែលគេរៀបចំសហករណ៍ធ្វើការងារធ្វើអីខ្លះ ហូបរួម?

ខន: នៅមូលដ្ឋានហ្នឹងឬ?

ទ្រី: បាទ!

ខន: នៅតាមភូមិហ្នឹងឬ?

ទ្រី: បាទ!

ខន: នៅទេ! នៅហូបតាមអាឡើយតើស ខ្ញុំចេញមកដឹងគេហូបរួមមិនរួម ខ្ញុំអត់ដឹងដែរព្រោះខ្ញុំមកនៅតាមអគ្គភាព គឺហូបរួមអីចឹងម៉ង ។

ទ្រី: អីចឹងមីងថានៅណុះក៏ធ្វើការរួមហូបរួម?

ខន: ហ្នឹងហើយ! គេលើកឡើងប្រាប់យើងអីចឹងណាមុនហ្នឹងគេយកយើងចេញមកហ្នឹងណា គេថាបើយើងមិនទៅឥឡូវនេះ ទោះបីជាយើងនៅខាងក្រោយហ្នឹងក៏យើង..។

ទ្រី: ហូបរួមស៊ីរួមហ្នឹងបានន័យថាម៉េច?

ខន: យើងដូចថាធ្វើស្រូវបានអីចឹងណា ...ហូបរួម ដូចថាក្នុងមួយកងអីចឹងវាមានគ្នាប៉ុន្មាននាក់ ៣០នាក់ ហូបបាយរួមជាមួយគ្នាទាំងអស់ ដាំហូបជារួម ។

ទ្រី: អាហ្នឹងម៉េចដែរល្អ ឬក៏អាក្រក់?

ខន: អត់ដឹងដែរប៉ុនតែអីចឹង ដឹងថាយើងចូលមកធ្វើបានធ្វើបានហូបរួមជាមួយគ្នាទៅ សល់ពីហូបដឹងម៉េច ដឹងយកទៅណា ខ្ញុំអត់ដឹងដែរ ។

ទ្រី: មីងកាលហ្នុងសប្បាយដែរឬ?

ខន: ចាំ!

ទ្រី: ហូបរួមអី?

ខនៈ ហ្អូ! នៅក្មេងៗអីចឹងអត់ដឹងទេ ចេះតែហូបទៅ ចេះតែនឹកផ្ទះអាលៃផ្ទះដូចតែគ្នាហ្នឹង ប៉ុន ដឹងធ្វើម៉េច ចេះតែនៅទៅ ។

ទ្រីៈ មីងមានដែលរត់មកផ្ទះទេអីចុង?

ខនៈ ចាំ!

ទ្រីៈ រត់មកផ្ទះ?

ខនៈ ខ្ញុំហ្នឹង អូ!ដែលនៅក្នុងនេះហ្នឹងហើយ អីមិនធ្លាប់តែនឹកផ្ទះរត់ហើយ... ។

ទ្រីៈ អីចឹងអាណាស្រួល បើមីងថាពេល...

ខនៈ អីចេះដូចថាយើងអាឡៃផ្ទះណា គេថាអត់ទាន់ឲ្យមកអីចឹងណា ។

ទ្រីៈ មីងរត់ចេញមកពីណា?

ខនៈ ពីមន្ទីរនៅហ្នឹង អង្គភាពនៅហ្នុង ។

ទ្រីៈ អង្គភាពណា?

ខនៈ អង្គភាពមន្ទីរ១៧ហ្នឹង ។

ទ្រីៈ កន្លែងណា?

ខនៈ ហ្នឹងព្រែកស្តីយើងហ្នឹង ហើនឹងខ្ញុំរត់ទៅផ្ទះទៅស្អាងស្រុកស្អាងយើងហ្នឹង នឹកផ្ទះសុំ អត់ហាន សុំគេរត់ទៅណា លួចទៅណា ។

ទ្រីៈ មីងអាកន្លែងហ្នឹងមីងដាក់ថាអាកន្លែងដែលចូល មូលហេតុដែលចូលបដិវត្តមីងនិយាយប្រាប់ គេណា?

ខនៈ ចាំ!

ទ្រីៈ មកពីមីងនឹកខឹងស្អប់ពួកលអាមេរិកកាំងវាឈ្លានពានកម្ពុជាទំលាក់ដីហីសម្លាប់ប្រជាជនកម្ពុជា យើង ហីមីងយល់ថាម៉េចដែរពី...?

ខនៈ អត់ទេ! កាលហ្នុងចុះរៀនអីចឹងចេះតែដាក់ទៅ ឲ្យតែរួចៗពីមាត់ ព្រោះនៅក្មេងដែរធ្វើ ម៉េច និយាយឲ្យតែហើយៗ កាលពីបច្ចុប្បន្នហ្នុង ចេះតែខ្លាចអាមេរិកកាំងហើយ ខ្លាច រឿងគ្រាប់បែកទម្លាក់ ។

ទ្រីៈ អីចឹងពួកវណ្ណៈសក្តិភូមិនោះមីង ថាខ្លាចពួកហ្នឹងដែរ?

ខន: ហីចុះដល់ពេល ខ្ញុំសួរឆ្ងល់ សុំសួរវិញចុះ ដល់ពេលបើកវគ្គបង្រៀនគេមិនលើកឡើងអំពីសក្តិភូមិជិះជាន់ ចាំ! របបចក្រពត្តិឈ្លានពាន់ ដូច្នេះហើយគេសួរយើងថា តើមានមតិយ៉ាងម៉េចខ្លះ ហីម្នោះហើយអ្នកឆ្លើយគេចេះតែឆ្លើយជាគំរូ ។

ទ្រី: អីចឹងគេបង្ហាបមីងខ្មែរក្រហមប្រាប់មីងរឿងសក្តិភូមិអីហ្នឹង ។

ខន: គេប្រាប់យើងអីចឹងទៅណា ថារបបជិះជាន់សក្តិភូមិ ចុះខ្ញុំនៅក្មេងដែរអីចឹង ខ្ញុំមានទៅដឹងអ្នកណាជិះជាន់ មិនជិះជាន់ ខ្ញុំដឹងតែនៅជាមួយម៉ែឪដឹងតែពីហូប ។

ទ្រី: ចុះប្រជាជន១៧មេសាគេប្រាប់ថាម៉េចខ្លះទៅ?

ខន: ១៧មេសា ប្រជាជនយើងហ្នឹងប្ញ?

ទ្រី: បាទ! គេប្រាប់ថាម៉េចទៅ ខ្មែរក្រហមបង្ហាបមីងថាម៉េចទៅ?

ខន: ប្រជាជនរំដោះចេញពីភ្នំពេញហ្នឹងប្ញ?

ទ្រី: បាទ!

ខន: អត់មាននិយាយថាម៉េច ឃើញតែទៅធ្វើការពលកម្មដូចគ្នាអីចឹង ។

ទ្រី: ខ្មែរក្រហមបំផុសឲ្យស្អប់ពួកហ្នឹងប្ញក៏អត់?

ខន: អត់មានលើករំលឹកថាស្អប់អីទេគ្រាន់តែថា គេប្រជាជនភៀសខ្លួនដឹងតែថាគេអ្នកភ្នំពេញគេស្រណុក ដឹងអីចឹង រឿងថាគេម៉េចៗអត់ ។

ទ្រី: មីងកាលហ្នឹងមីងទទួលស្គាល់ថាមីង គេបង្ហាបមីងឲ្យស្អបពួកវណ្ណៈសក្តិភូមិ ស្អប់អីមីងទទួលស្គាល់ថាកាលហ្នុងយើងស្អប់មែនទេ?

ខន: គេមានលើកឡើងនា ឧទាហករណ៍ថាគេលើកឡើងថាវណ្ណៈអស់នេះ ឧទាហករណ៍ថាវណ្ណៈសក្តិភូមិ គេជិះជាន់អ្នកក្រីក្រយើងណាស់ ហ្នឹងហើយគេធ្វើជាមេរៀនឲ្យយើងរំលឹកថាត្រូវស្អប់ពួកហ្នឹងណា វណ្ណៈហ្នឹងជិះជាន់អ្នកក្រីក្រ អីចឹងគេលើកឡើងពីរៀនអីចឹងណាំ ដល់ពេលយើងឆ្លើយវិញ អាហ្នឹងយើងឆ្លើយថាអីចឹង... ។

ទ្រី: ប៉ុន្តែចិត្តយើងណា?

ខន: ចុះបើនៅក្នុងរបបហ្នឹង គេបង្រៀនអីចឹងហើយ យើងមានខួរក្បាលណារបបថ្មីណាចូលអត់ទេ ដូច្នេះនៅក្នុងរបបហ្នឹងអីចឹងប្ញ ដូចយើងសព្វថ្ងៃអីចឹង ។

ទ្រី: ត្រូវ! យល់ៗ

ខន: ចាំ! អាហ្នឹងនៅក្មេងអីចឹង ។

ទ្រី	ចុះដល់ពេលឥឡូវវិញមីងយល់ថាការនិយាយហ្នឹងត្រូវ ឬក៏ខុស?

ខន:	ឥឡូវខ្ញុំនឹកឃើញអីចឹង នឹកឃើញថាយើងស្អប់វណ្ណៈជិះជាន់ហើយ បើគេមានៗអីចឹងហើយដឹងធ្វើម៉េច គេរកបាន គេមិនមាន ហីបើយើងអ្នកធ្វើស្រែចេះតែធ្វើ ប៉ុនគ្រាន់ថារបបយើងបានរបស់របបលក់វាថោកអីចឹងទៅណា ចេះតែនឹកឃើញវាស្តាយរបស់អីចឹងវិញទៅ មានទៅនឹកឃើញអ្នកណាជិះជាន់...សើច..

ទ្រី:	អីចឹងមីងអត់ដែរឮ គេប្រជុំថាអូយ! ជួយសីហនុ ជួយអីឲ្យបានចូលស្រុកវិញទេ?

ខន:	អត់! អាហ្នឹងខ្ញុំរត់ទៅបាត់ហើយ មានទៅជួយ...។

ទ្រី:	ពេលមីងរត់មកផ្ទះពីមន្ទីរ១៧ហ្នឹង អត់មានអ្នកណាធ្វើបាបមីងអីទេ។

ខន:	អត់ទេ! រត់ទៅគេទៅហៅមកវិញមក គេទៅប្រាប់ថាទៅកន្លែងវិញ ខ្ញុំមកវិញមក។

ទ្រី:	មីងកាលហ្នឹងម៉េចបានមានហេតុការណ៍ទម្លាក់គ្រាប់បែក ហេតុម៉េចបានមានការប្រយុទ្ធគ្នា?

ខន:	អត់ដឹងគ្រាន់ដូចថាកប៉ាល់ហោះ ហោះមកយកការ ហ្នុងខ្ញុំវានៅស៊ើដែរទេ កប៉ាល់ហោះមកយកការអីចឹងទៅ ហើយបន្តិចឃើញអាកប៉ាល់ហោះហ្នឹងមកទម្លាក់ទៅ អីចឹងបានជាឆ្ងល់ដែរមិនដឹងជាទម្លាក់រឿងអី វាចេះតែអ្នកស្រុករត់ចូលត្រង់សេហ្នុងទៅ។

ទ្រី:	រហូតដល់សព្វថ្ងៃហ្នឹងមីងយល់ទេ ម៉េចអីចឹង?

ខន:	ខ្ញុំដូចជាអត់ចាប់អារម្មណ៍យល់ថាម៉េច ខ្ញុំអត់មានចិត្តនឹកឃើញអី នឹកឃើញតែប្រកបមុខរបររកស៊ី។

ទ្រី:	មីងកាលហ្នុងគេមានបង្រៀន ខ្មែរក្រហមមានបង្រៀនយើង ថាអូ! សិទ្ធិនារីសិទ្ធិបុរសយើងស្មើរគ្នា?

ខន:	ចេះតែលើកដែរតើស។

ទ្រី:	គេនិយាយថាម៉េចខ្លះ?

ខន:	គេគ្រាន់តែនិយាយថាបុរសយើង សម្រេចការងារបាន យើងស្រីក៏អាចមានលទ្ធភាពនិយាយតវ៉ាដែរ ដូចគ្នាអីចឹងទៅណា...។

ទ្រី:	អាហ្នុងអីចឹងមែនឬមីងកាលហ្នុង ប្រុសធ្វើអីក៏បានស្រីធ្វើដែរ?

ខន:	ចា៎! ហ្នឹងហើយវាគ្រាន់តែលើកឡើងអីចឹងថា បុរសអាចសម្រេចការងារបាន យើងស្រីក៏អាចធ្វើបានដែរ គេលើកឡើងតែប៉ុណ្ណឹង។

# មជ្ឈមណ្ឌលឯកសារកម្ពុជា

## សម្ភាសន៍ជាមួយ ឆេង សាភឿន នៅភូមិក្បាលជ្រោយ ឃុំពោធិ៍បាន ស្រុកកោះធំ ខេត្តកណ្ដាល ថ្ងៃទី១៣ ខែសីហា ឆ្នាំ២០០២

ទ្រី: មីងឆ្នាំហ្នឹងអាយុប៉ុន្មានហើយមីង?

ភឿន: ខ្ញុំជាង៤០ហើយ ។

ទ្រី: ៤០ប៉ុន្មានទៅ?

ភឿន: ៤៦ហើយ ។

ទ្រី: មីងកាលពីជំនាន់ខ្មែរក្រហមពុជាមានទម្លាក់គ្រាប់បែក កាលពីជំនាន់មុនខ្មែរក្រហមនៅក្នុងភូមិក្នុងអីហ្នឹង?

ភឿន: កាលពីជំនាន់ខ្មែរក្រហម៧៣ទម្លាក់គ្រាប់បែបហ្នឹង ប្រ៥២ ។

ទ្រី: មីង! ចុះពេលហ្នុងមានកងទ័ពនៅក្នុងភូមិបានទម្លាក់គ្រាប់បែកហ្នឹង?

ភឿន: ដូចអត់មានផង ប៉ុនទម្លាក់មកមិនដែលទម្លាក់ចំភូមិទេច្រើន...

ទ្រី: មីងកាលហ្នឹងកើតជានៅភូមិហ្នឹងម៉ង?

ភឿន: ចា៎!

ទ្រី: ភូមិអីហ្នឹង?

ភឿន: ភូមិល្អៅ ពីដើមគេភូមិក្បាលជ្រោយ ។

ទ្រី: ហើកាលហ្នឹងពេលដែលមីងកើតជាមក មីងឃើញកងទ័ពចូលមកក្នុងភូមិយើង កងទ័ពហ្នុងទ័ពស្អី?

ភឿន: កាលហ្នឹងច្រើនមិនដឹងទ័ពខាងខ្លះទេ... ។

ទ្រី: មីងកាលហ្នឹងចេញពីផ្ទះទៅធ្វើជាមួយខ្មែរក្រហមអាយុប៉ុន្មាន?

ភឿន: អាយុ១៥ឆ្នាំ ។

ទ្រី: កាលហ្នឹងឆ្នាំណាមីង?

ភឿនៈ ខ្ញុំចេញទៅឆ្នាំ៧៣ ។

ទ្រីៈ ម៉េចបានកាលហ្នឹងបានមីងទៅមីង?

ភឿនៈ ចាំ!

ទ្រីៈ ម៉េចបានមីងចេញកាលហ្នឹង រឿងរ៉ាវអាម៉េចបានមីងមីងចេញទៅ?

ភឿនៈ ដូចមិនដឹងមានរឿងអីផង សើច...

ស្រីៈ គេឲ្យចេញក៏ចេញ ។

ភឿនៈ គេឲ្យទៅមុនដំបូងគេថាយើងមិនហានទៅមុខហ្នឹងគេ យើងទៅតែលក់ដូរទៅ ត្រឹមពាណិជ្ជពាអីណា នៅក្នុងភូមិទេ ។

ទ្រីៈ មីងកាលហ្នឹងគេប្រាប់មីងអីចឹង មីងក៏សម្រេចចិត្តចូលទៅ?

ភឿនៈ សម្រេចចូលទៅទៅ ។

ទ្រីៈ មីងកាលហ្នឹងសប្បាយចិត្តចង់ចូលដែរ កាលហ្នឹងចង់ចូលដែរ?

ភឿនៈ អត់! អត់មានចង់ចូល ប៉ុនថា នឹកកាលហ្នឹង បើមិនទៅក៏គេនៅតែហៅទៅ ហើយឃើញថាធ្វើការងារជិតហើយ ទៅៗ ទៅរវល់តែរត់មកផ្ទះ ។

ទ្រីៈ កាលហ្នឹងអ្នកណាអ្នកហៅហើយឲ្យចូល មកប្រាប់យើងអីចឹងមីង?

ស្រីៈ កាលជំនាន់ហ្នុងខ្លាចចង់តែងាប់ ។

ភឿនៈ គេអ្នកប្រាប់ហ្នុងគេស្លាប់អស់ហើយ ។

ទ្រីៈ ប្រធានភូមិ ប្រធានឃុំឬក៏ម៉េច?

ភឿនៈ ប្រធានតំណាងនារីសង្កាត់ ប៉ុនស្លាប់បាត់ហើយ បង...ហ្នុងស្លាប់បាត់ហើយ ។

ទ្រីៈ ឈ្មោះអី យ៉ុនហ្នឹងមែនទេ?

ភឿនៈ ទេកាលហ្នុងបងសាមុត ប៉ុនបងយ៉ុនក៏មក ឈ្មោះយ៉ុន ។

ស្រីៈ ប៉ុនងាប់អស់ហើយហ្នឹង ។

ភឿនៈ ប៉ុនងាប់អស់រលីញហើយ ហឹដាក់ហ្នុងថាឈ្មោះយ៉ុន ។

ទ្រីៈ មីងកាលហ្នឹងមីងដាក់នៅក្នុងប្រវត្តិរូប ថាមូលហេតុដែលខ្ញុំចូលបដិវត្តដោយសារខ្ញុំចង់រំដោះខ្លួនពីការគាបសង្កត់ ដូចថារើបំរ៉ាស់ឲ្យផុតពីការជិះជាន់របស់វណ្ណៈសក្តិភូមិ?

ភឿនៈ ធ្វើកាំងភូមិទៅ.... ។

ទ្រីៈ មីងប្រាប់គេថាអីចឹងម៉ង?

ភឿនៈ ប្រាប់គេថាអីចឹងហើយ?

ទ្រីៈ អីចឹងមីងដាក់អីចឹងដែរ ព្រោះកាលហ្នឹងមីងសប្បាយចិត្តនឹងរំដោះប្រជាជនអី មែនឬក៏យ៉ាងម៉េច?

ភឿនៈ សប្បាយចិត្តរំដោះអីចឹងមែនប៉ុនទៅមិនដឹងទៅធ្វើអីទេ សើច...។

ទ្រីៈ អីចឹងមីងសប្បាយចិត្តហ្នឹងចូលដែរព្រោះមីងចង់រំដោះប្រជាជន ហើយចូលទៅអាចរំដោះប្រជាជនបាន ចង់ចូលដែរកាលហ្នុង?

ភឿនៈ កាលហ្នឹងគេសួរយើងអីចឹងឲ្យឆ្លើយ តើយើងស្មោះត្រង់ហ្នឹងអត់ គេសួរយើងហ្នឹងណាហីបើយើងឆ្លើយខុសពីអីចឹង ថាយើងអត់ស្មោះត្រង់នឹងគ្នា ថាអីចឹងណា ។

ទ្រីៈ ចុះគេប្រាប់មីងថាម៉េចខ្លះ ជាចក្រពត្តិឬម៉េចបានយើងឆ្លើយអីចឹង?

ភឿនៈ គេប្រាប់ខ្ញុំថាពីរឿងសក្តិភូមិនាយទុន រកស៊ីគាបសង្កត់ប្រជាជននឹងណា ។

ទ្រីៈ អីចឹងមីងខឹងគេដែរទេមីង ពួកអ្នកមានអ្នកអីហ្នឹង?

ភឿនៈ កាលហ្នឹងអ្នកណាដូចអ្នកណា ដូចមិនដឹងគេខឹងអ្នកណា ធម្មតា ។

ទ្រី ពេលដែលមីងគេបង្កបញ្ឆោមីងឲ្យស្អប់ឲ្យស្អីហ្នឹងអារម្មណ៍របស់មីងម៉េចដែរជឿតាមគេមែនស្អប់មែនឬក៏ម៉េច?

ភឿនៈ បេះតែជឿគេហើយថាគេល្អ មិនដឹងថាគេល្អ អាក្រក់មិនដឹងដែរ ។

ទ្រីៈ អីចឹងពេលដែលពួថាខ្មែរក្រហមចូលមក មីងថាតែខ្មែរក្រហមល្អចង់ជួយអ្នកក្រ?

ភឿនៈ ចាំ!

ទ្រីៈ អីចឹង?

ភឿនៈ ចុះបើគេឃោសនាថា មករំដោះប្រជាជន គេឃោសនាគោលជំហរឲ្យយើង ។

ទ្រីៈ គេនិយាយផាម៉េចខ្លះអារឿងអ្នកក្រអ្នកមានអីហ្នឹង?

ភឿនៈ សើច...គេគ្រាន់ថាអីចឹង យើងមិនដឹងថាជឿគេរបៀបម៉េច ។

ទ្រីៈ មីងកាលហ្នឹងពេលដែលខ្មែរក្រហមនិយាយអីចឹងតើគេធេវីអីចឹងមែនឬ ជួយអ្នកក្រជួយអីជួយមែនទែនឬ?

ភឿនៈ កាលម៉ាជិនាទ់ហ្នងមិនទាន់ឃើញថបានថាជួយអីផង ប៉ុនគ្រាន់ថាតែគេឃោសនាអីចឹងណាខ្ញុំវាក្មេចដែរហើយ ខ្ញុំវាស្ទើរក្មេងៗ...។

ទ្រីៈ មីងចង់និយាយថាម៉េចអាឃោសនាហ្នឹង?

ភឿនៈ ដូចថាគេថា ដែលគេមករំដោះប្រជាជន គេមកជួយធ្វើសង្គ្រាមអីចឹងណា ។

ទ្រីៈ អីចឹងមីងជឿដែរពេលហ្នឹង?

ភឿនៈ គេដឹកនាំ ខ្ញុំចេះតែជឿតាមហ្នឹងទៅ ម៉ាជំនាន់ហ្នឹងមិនថាអ្នកណាអ្នកណីទេ នៅក្រោមការដឹកនាំរបស់គេ ។

ទ្រីៈ គេអត់មាននិយាយថាមកជួយរំដោះសីហនុអីគេ?

ភឿនៈ អត់មាននិយាយទេ គេនិយាយរំដោះប្រជាជន ។

ទ្រីៈ ចុះគេមាននិយាយពីទាហានលន់ ណុល ម៉េចមួយអីចុះពីរអីទេ?

ភឿនៈ អត់! ខ្ញុំនៅតូចខ្ញុំមិនដឹង ។

ទ្រីៈ គេមាននិយាយពីទាហាន លន់ ណុល ពីទាហានអាមេរិកកាំងអីទេ?

ភឿនៈ អត់ដែរជួបព្រោះខ្ញុំនៅ ថាទៅលក់ដូរហ្នឹង ដូចថាទៅលក់ដូរក្បែរ មិនសូវដឹងអី ម៉ាជំនាន់ហ្នឹងអត់ដឹង ។

ទ្រីៈ មីង! ហ្នឹងទម្លាក់គ្រាប់បែកនៅភូមិទម្លាក់របៀបម៉េច?

ភឿនៈ ទម្លាក់អីចឹងមែនគ្រាប់បែក ប៉ុនវាអត់ដែរចំភូមិដង បេ៥២វាច្រើនចាក់ទៅក្នុងព្រៃ ។

ទ្រីៈ អីចឹងកាលហ្នឹងខ្លាចដែរឬអត់សូវអីទេ?

ភឿនៈ និយាយមិនខ្លាចម៉េច គ្រាប់បែកមកពីលើហើយនិយាយមិនខ្លាចអាម៉េច ។

ទ្រីៈ អ្នកណាគេទម្លាក់គ្រាប់បែកហ្នឹង?

ភឿនៈ មិនដឹងដែរ អត់ដឹងខាងណាៗទេ អត់ស្គាល់ ។

ទ្រីៈ ចុះខ្មែរក្រហមនិយាយថាជួយប្រជាជនរំដោះប្រជាជន ហើរឹកម្ទេចពួកអ្នកទម្លាក់គ្រាប់បែកហ្នឹងមែនទេ?

ភឿនៈ ដឹងរឿងខាងណាៗទេ ខ្ញុំវានៅស្មើរដែរវាមិនចាំ ។

ទ្រីៈ មីងអត់ដឹងម៉ងឬ?

ភឿនៈ អត់!

ទ្រីៈ ឬក៏អត់ចាំ?

ភឿនៈ វាអត់ចាំ អត់ដឹងវាទម្លាក់ហ្នឹងមិនដឹងពួកណាអីពួកណា ។

ទ្រីៈ មីងកាលហ្នឹង មីងចូលខ្មែរក្រហម មីងអត់ឲ្យទៅរៀនទៅសូត្របំពាក់បំប៉ននយោបាយអីទេ?

ភឿនៈ អត់! ទៅតែធ្វើការងារធម្មតា មិនដឹង ។

ទ្រីៈ អីចឹងពេលណា ដែលមីងព្ទុថាចក្រពត្តិនិយម វណ្ណៈជិះជាន់អី មីងដឹងទេ?

ភឿនៈ .....ភ្លេចអស់ហើយដឹងណាណីទេ មិនចាំព្រោះកាលហ្នុងវាឈឺ ឈឺធ្ងន់ពេករឿងអីចឹងមិនដឹង ។

ទ្រីៈ ខ្មែរក្រហមមានប្រាប់ថាអូ! បុរសហីស្រីមានសិទ្ធិស្មើរគ្នាអី?

ភឿនៈ កាលហ្នុងប្រាប់ហើយ បុរស នារីគេយកសិទ្ធស្មើរគ្នា ដើម្បីឲ្យនារីទៅធ្វើការងារស្មើរហ្នឹងយុវជនណា ។

ទ្រីៈ មីងគិតថាល្អទេអាការដែលចង់ស្រី និងបុរសធ្វើការដូចគ្នា មានសិទ្ធិស្មើរគ្នា?

ភឿនៈ មានអីល្អ បើស្រ្តីគ្នាទន់ខ្សោយ ហីឲ្យធ្វើការងារស្មើរគ្នាអីចឹង ប៉ុន្តែជមនន់ហ្នឹងវាធ្វើបេះតែធ្វើទៅ បើមិនធ្វើវាបេះតែខ្លាចគេណា ។

ទ្រីៈ មីងអាពេលដែលមីងចូលលក់ដូរឲ្យខ្មែរក្រហមហ្នឹង ធ្វើការឲ្យខ្មែរក្រហមហ្នឹងវាល្អអាម៉េចស្រួលអាម៉េច ពីបាកអីអាម៉េចការងារអី?

ភឿនៈ ដូចអត់មានងីពិបាកផង គេយកមកឲ្យលក់បេះតែលក់ទៅលក់សព្ទ លក់គ្រប់តាំងពី...ស្កបីចេងអីចឹងទៅ អត់មានពិបាកអី ត្រូវណាគេយកដំណាំគេយកបន្លែ ផ្លែឈើអីយកមកលក់ទៅ សព្ទគ្រប់ដឹងស្អីជាស្អីទេ ។

ទ្រីៈ អីខ្លះមីង បន្លែ បន្ទុកអី ស្អីខ្លះទៀត?

ភឿនៈ មានសព្ទ តាំងពីក្រណាត់ តាំងពីអីហ្នឹង ក្រណាត់ទាំងកីៗអីចឹង ។

ទ្រីៈ ខោអាវ?

ភឿនៈ ខោអាវអត់មានទេ មានតែក្រណាត់ ក្រណាត់សព្ទមុខទៅ គេយកមកវាស់លក់ទៅ ។

ទ្រីៈ ស្អីមីង ស្អីទៀតទៅ?

ភឿនៈ មានទាំងពីអបោះដេរ មានស្ក បីចេង ទឹកត្រីអី សៀងអី អំបិលលក់សព្ទ ដូចយើងលក់ចាប់ហួយអីចឹង ។

ទ្រីៈ អីចឹងមីងអ្នកលក់ដូរឲ្យខ្មែរក្រហម?

ភឿនៈ អត់ទេ! លក់ឲ្យប្រជាជនក្នុងភូមិហ្នឹង ។

ទ្រីៈ ប៉ុនយកលុយឲ្យខ្មែរក្រហមណ៎?

ភឿនៈ អុឺ! ដឹងយកលុយឲ្យខ្មែរក្រហម ដឹងយកអីផង គេថារដ្ឋៗដឹងរដ្ឋអីសើច...ជំនាន់ហ្នុងដូច គ្មានខ្មែរក្រហមឯណាគ្រាន់តែលក់ មិនទាន់មានខ្មែរក្រហមទេកាលហ្នុង គ្រាន់តែលក់យក គេថាលក់ឲ្យលុយរដ្ឋណា ដូចថាទំនិញរបស់រដ្ឋណា ។

ទ្រីៈ ពេលដែលមីងចូលភ្នាមហ្នុងមីងធ្វើអីគេ?

ភឿនៈ លក់ហ្នុង ។

ស្រីៈ ហើយគេឲ្យប្រាក់ខែទេ?

ភឿនៈ មានប្រាក់ខែស្អី! បានតែម៉ាហូបតែបាយ.... ។

ទ្រីៈ អីចឹងមីងបានលុយដែរ?

ភឿនៈ អត់!

ទ្រីៈ នេះ! និយាយលក់ហ្នឹងទទួលលុយមកឬ?

ភឿនៈ លក់ហ្នឹង!

ទ្រីៈ លក់ឲ្យគេ ដូចថាដូរជាអី?

ភឿនៈ លក់ហ្នុង ដូចថាយើងលក់អីចឹងទៅ មានគេ គេទទួលលុយផ្សេងទៅណា យើងគ្រាន់ថាជា កម្មកររបស់គេលក់ត្រង់ហ្នឹងណា ។

ស្រីៈ គេគ្រាន់តែប្រើឲ្យលក់ឲ្យគេណា ។

ភឿនៈ គេគ្រាន់តែប្រើឲ្យលក់ណា ប៉ុន្តែលុយកាក់គេកាន់កាប់ យើងអត់ប៉ះទេ ហីលក់ហ្នឹងមិនមែន លក់ឲ្យខ្មែរក្រហមណា កាលហ្នឹងជំនាន់ហ្នឹងអត់មានខ្មែរក្រហម លក់ឲ្យប្រជាជនទូទៅនៅ ក្នុងភូមិ ប្រជាជនណាក៏ទៅទិញដែរ ។

ទ្រីៈ ចុះពេលដែលរបបខ្មែរក្រហមមីងធ្វើវិញ?

ភឿនៈ របបខ្មែរក្រហមខ្ញុំនៅរោងចក្រ របបខ្មែរក្រហមខ្ញុំនៅកសាងសំណង់នៅបឹងស្រយ៉ាបនៅ ខាងណោះទួលគោក ទល់មុខរោងចក្រ...កាលហ្នុងគេហៅរោងចក្រអូរមួយ ។

ទ្រីៈ មីងកាលហ្នឹងចូលធ្វើបដិវត្តហ្នឹងឆ្នាំ១៩៧៣ឬ?

ភឿនៈ ៧៣ចូល ។

ទ្រីៈ អីចឹងមីងចេញពីផ្ទះឆ្នាំហ្នឹងដែរ?

ភឿនៈ ចេញឆ្នាំហ្នឹង ប៉ុនចេញនៅជិតហ្នឹងណា ។

ទ្រីៈ ពេលហ្នឹងមីងធ្វើអី?

ភឿនៈ ចាំ!

ទ្រីៈ ពេលមីងចេញពីភូមិជិតៗហ្នឹង ចេញពីផ្ទះជិតៗនៅក្នុងភូមិហ្នឹងធ្វើអីគេ?

ភឿនៈ លក់ហ្នឹង! ពីដើមគេហៅពាណិជ្ជរដ្ឋ ។

ទ្រីៈ អីចឹងមីងពេលធ្វើការដំបូងចេញពីភូមិហ្នឹង មុនដំបូងនៅជិតៗទេ ដល់ក្រោយមកបានចេញទៅឆ្ងាយ ឆ្នាំ៧៥បានចេញទៅនៅឆ្ងាយ ។

ភឿនៈ ឆ្នាំ៧៥បានចេញទៅនៅរោងចក្របីងស្រយាំបខាងកើតពោធិ៍ចិនតុងហ្នឹង ។

ទ្រីៈ អីចឹងមីងក្រៅពីលក់ដូរអត់មាន អត់មានធ្វើដាំដុះដំណាំ បង្កបង្កើនផលអីទេ?

ភឿនៈ ចាំ!

ទ្រីៈ លក់តែដូររហូត?

ភឿនៈ លក់!

ទ្រីៈ មីងពេលដែលលក់ដូរនៅភូមិហ្នឹង ប្រុសហីស្រីមានធ្វើការជាមួយគ្នាដែរ ឬក៏មានប្រុសដោយប្រុស?

ភឿនៈ ដូចថាក្នុងម៉ាមន្ទីរពាណិជ្ជមួយ គេឲ្យប្រុសម្នាក់ហ្នឹងសម្រាប់ធ្វើការងារធ្ងន់ដូចថារែកទឹកត្រីដូចថាម៉ាកាដុង៣០លីត្រ រែកទៅយកទៅចាក់ពាងអីចឹងទៅ ស្រីៗ គេអង្គុយលក់អីទៅ ។

ទ្រីៈ អីចឹងនៅអីរស់នៅអីជាមួយគ្នាអីចឹងទៅ?

ភឿនៈ នៅជាមួយគ្នាស្រី៣នាក់ ប្រុសម្នាក់ ។

ទ្រីៈ មីងកាលហ្នឹងបានមកផ្ទះលេងដែរឬ ពេលនៅលក់ដូរអីហ្នឹង?

ភឿនៈ ពេលលក់ដូរជិតអីចឹងចេហតែមកលេងហើយ ហីទៅឆ្ងាយចេះតែលួចរត់មកផ្ទះ ។

ទ្រីៈ ពេលមីងនៅក្នុំពេលនៅតែរត់មកផ្ទះដែរឬ?

ភឿនៈ នៅមក!

ទ្រីៈ មីងគេអត់ធ្វើបាបមីងចេះទេ ឬខ្មែរក្រហម ពេលរត់មកអីចឹង?

ភឿនៈ គេមិនធ្វើបាបយើងទេ ប៉ុនគ្រាន់ថាដឹងយើងមកលេងផ្ទះញឹកអីចឹងគេបញ្ជូនយើងឲ្យចេះតែទៅឆ្ងាយទៅៗ ។

ទ្រីៈ អត់គេអត់មានប្រាប់យើងថា អូ! មិនបាច់គិតគូផ្ទះសម្បែងអីទេ គេសុខសប្បាយទេ?

ភឿនៈ គេប្រាប់ដែរ គេថា មិនបាច់គិតគូទេម៉ែឪមានគេជួយក្រោយៗហើយ ។

ទ្រីៈ ចុះមីងពេលគេប្រាប់អីចឹងម៉េចដែរ?

ភឿនៈ ប្រាប់អីចឹងប៉ុនអារម្មណ៍នៅតែនឹកម៉ែនឹកឪ ។

ទ្រីៈ អីចឹងគេអត់ចង់ឲ្យយើងរស់នៅជាមួយគ្នា ចង់ឲ្យបំបែកបំបាក់គ្នាឬ?

ភឿនៈ គេមិនចង់ឲ្យយើងមកផ្ទះជួបម៉ែឪ ចង់ឲ្យយើងនៅធ្វើការឲ្យគេទៅណា ។

ទ្រីៈ អាហ្នឹងល្អទេមីង?

ភឿនៈ ថាម៉េច?

ទ្រីៈ អាការមិនឲ្យយើងមកផ្ទះ នៅតស៊ូហ្នុងរហូត ។

ភឿនៈ ថាអូ! បើចិត្តយើងចង់នឹកម៉ែឪហើយ ហីគេចេះតែគំហកឲ្យយើងរឿងការងារជំនាន់ហ្នុង ។

ទ្រីៈ មីងអត់ដែរទៅសរមេភូមិមុខទេអីចឹងនៅតែក្រោយរហូត?

ភឿនៈ អត់! អត់ស្គាល់សមរភូមិម៉េចផងទេ សើច...ខ្លាចយ៉ាងនេះ តែងាប់ៗរហូតហើយ ដោយសារតែខ្លាចហ្នឹងហើយបានសុខចិត្តនៅលក់ដូរនៅនេះអត់ទៅណា ។

ទ្រីៈ មីងកាលហ្នុង ស្រីនៅក្នុងរបបខ្មែរក្រហមគេយកចិត្តទុកដាក់ដែរ?

ភឿនៈ កន្លែងគេផ្សេងខ្ញុំមិនដឹងដែរ បើកន្លែងខ្ញុំអត់មានធ្វើបាបដែរ ។

ទ្រីៈ មីងកាលហ្នុងមានបានទៅរៀនទៅអីណាកាលពីនៅក្មេង?

ភឿនៈ រៀនអក្សរ រៀនក្នុងសាលា?

ទ្រីៈ បាទ!

ភឿនៈ បាន ។

ទ្រីៈ អានបានមីង?

ភឿនៈ អានបាន ។

ទ្រីៈ មីងកាលហ្នុងដល់ក្រោយមកទៀតមានដែរឃើញ ឬក៏ទស្សនាវដ្តីបដិវត្តន៍របស់ខ្មែររកហម សៀវភៅនយោបាយខ្មែរក្រហមអី?

ភឿនៈ អត់!

ទ្រីៈ មីងមានឮវិទ្យុផ្សាយរបស់ខ្មែរក្រហមអីទេកាលជំនាន់ហ្នុង?

ភឿនៈ ឮៗហើយ ប៉ុនមិនដឹងគេផ្សាយស្អីផង មិនសូវយលចិត្តទុកដាក់ អត់ ។

ទ្រីៈ ចុះគេមានបង្រៀននាំយើងច្រៀងចំរៀងបដិវត្តខ្មែរក្រហមអីទេ?

ភឿនៈ អត់!

ទ្រីៈ មីងកាលមានដែលឮគេច្រៀងអីដែរចំរៀងអស់ហ្នឹង?

ភឿនៈ អត់....

ធ្វើៈ មីង! កាលមីងធ្វើការនៅភូមិហ្នឹងអ្នកណាគេធ្វើប្រធានយើង លក់ដូរ លក់អីភូមិហ្នឹង អ្នកណាគេធ្វើប្រធាន?

ភឿនៈ និយាយរឿងប្រធានភូមិ?

ធ្វើៈ អត់ទេ! អ្នកគ្រប់គ្រងមីងនៅកន្លែងលក់ដូរ?

ភឿនៈ បងហ៊ុង គាត់ស្លាប់ហើយ ចុះពីបងហ៊ុង មកបង ដេង ។

ធ្វើៈ ស្រីឬ?

ភឿនៈ ស្រី! ស្លាប់អស់រលីងហើយ ។

ធ្វើៈ មនុស្សល្អដែរទេឬពួកហ្នឹង?

ភឿនៈ មនុស្សល្អ ប៉ុនស្លាប់អស់ហើយ តាំងទៅមិនដែរជួបប្រទះរឿងអាក្រក់ៗសោះ កន្លែងគេ មិនដឹង កន្លែងខ្ញុំអត់ ។

ធ្វើៈ មីងអត់ដែលមានឮអ្នកណាសម្លាប់មនុស្សអីទេពេលមីងធ្វើការជាមួយខ្មែរក្រហមនៅកន្លែង ភ្នំពេញណា?

ភឿនៈ អត់! ដឹងតែពីធ្វើ មិនដែលឮពីរឿងថាអ្នកណាសម្លាប់អ្នកណាអត់ ដល់ពេលគាត់សម្លាប់រួច ហើយបានមាន ។

ធ្វើៈ មីងហូបចុកអីគ្រប់គ្រាន់គួរសម?

ភឿនៈ ហូបចុកអីគ្រប់គ្រាន់ទេ ពួកកន្លែងខ្ញុំកន្លែងក្រសួងកសិកម្មហ្នឹងហូបចុកអត់សូវដែរ ។

ធ្វើៈ មីងកាលហ្នឹងមីងទៅភ្នំពេញឆ្នាំ៧០ប៉ុន្មាន ។

ភឿនៈ ៧៥ ។

ធ្វើៈ មីងដំបូងធ្វើអីពេលទៅដល់ភ្នំពេញ មានដុះដុះលាងផ្ទះ...?

ភឿនៈ នៅភ្នំដំបូងគេឲ្យនៅត្រឹមតាខ្មៅ គេឲ្យលាងបោសសំអាតណាដូចផ្ទះប្រជាជនគេជម្លៀស ចេញមកអស់ណា ជម្លៀសចេញមកអស់អីចឹងនៅតែផ្ទះអីចឹងគេបោសសំអាតសំរាមស្អីៗ ហ្នឹងកុំឲ្យមាននៅលើផ្ទះហ្នឹងណា ។

ធ្វើៈ ហើយបន្ទាប់ទៀត?

ភឿនៈ ហើយបន្ទាប់មកទៀត គេឲ្យខ្ញុំមកនៅរោងចក្រកសាងសំណង់ ។

ធ្វើៈ ប៉ុន្មានខែនៅបោសផ្ទះបោសអីហ្នឹង?

ភឿនៈ មួយឆ្នាំដែរ ដល់ម៉ែខ្ញុំទៅលេងខ្ញុំមកតាមម៉ែខ្ញុំ គេឱ្យខ្ញុំអត់ឲ្យនៅហ្នឹង គេឲ្យទៅទៀតទៅ ។
ទ្រីៈ បន្ទាប់មកគេឲ្យទៅទៀតទៅដល់ណា?
ភឿនៈ ទៅនៅក្រសួងកសិកម្ម នៅតែកសាងសំណង់រោចក្រហ្នឹង ។
ទ្រីៈ អីចឹងមីងនៅហ្នឹងប្រហែលបានប៉ុន្មានឆ្នាំ ធ្វើរោងចក្រហ្នឹង?
ភឿនៈ នៅរោងចក្រហ្នឹងប្រហែលជាប់៣ឆ្នាំដែរ បានរើចេញ ។
ទ្រីៈ ការងារនៅហ្នឹងស្រួលទេអត់អីទេ សប្បាយទេ?
ភឿនៈ ការងារនៅរោចក្រហ្នឹងមានអី គេចែកជាក្រុមៗ មានក្រុមបូកអីចឹងទៅ មានម៉ាស៊ីន
លាយសំណង់ពីចឹងទៅ មានក្រុងជញ្ជូនថ្ម មានខ្វះលាងថ្ម ។
ទ្រីៈ ប្រធានមីងអត់អីទេល្អដែរ?
ភឿនៈ ប៉ុនគេនៅឆ្ងាយ ។
ទ្រីៈ មនុស្សល្អទេ?
ភឿនៈ មនុស្សល្អទេ ។
ទ្រីៈ ស្រី ឬប្រុសមីង?
ភឿនៈ គេនៅខាងខត្តុក្តណុះស្រី ។
ទ្រីៈ ឈ្មោះអីទេ?
ភឿនៈ នារី! ឈ្មោះអីទេភ្លេចហើយ ។
ទ្រីៈ ធ្វើការពីម៉ោងប៉ុន្មានដល់ម៉ោងប៉ុន្មានចេញចូល?
ភឿនៈ ម៉ោង៧ចូល ម៉ោង១១ចេញមកហូបអី ហូបបាយអីហើយម៉ោង២ចូលទៅវិញទៀតទៅ ។
ទ្រីៈ រហូតដល់ម៉ោងប៉ុន្មាន ម៉ោង២ចូលម៉ោងប៉ុន្មានចេញមកវិញ?
ភឿនៈ ម៉ោង៥ ។
ទ្រីៈ ក្រោយមកលែងធ្វើហើយ អត់តដល់យប់អីទៀតទេ?
ភឿនៈ យប់គេធ្វើដែរ គេធ្វើត្រឹមម៉ោង៧ ទល់និងម៉ោង៩ ។
ទ្រីៈ ពេលយប់ឬ?
ភឿនៈ ចា៎!
ទ្រីៈ ធ្វើការច្រើនម៉ោងដែរអីចឹង?
ភឿនៈ ចា៎!

ទ្រី: ការងារអត់សួរហត់ទេ?

គឿន: អត់លំបាកទេ គេធ្វើមានក្រុមអីចឹងស្រួលទេ អីចឹងជំនាន់ហ្នឹងថាកន្លែងគេខ្វះថា លំបាក ខ្ញុំកន្លែងខ្ញុំស្រួល អត់ទាន់ជួបកន្លែងពិបាក សើច...។

ទ្រី: គេឲ្យយើងលេងសើចជាមួយមិត្តភក្តិក្នុងក្រុមការងារអីនិយាយបានធម្មតាទេ?

គឿន: មានអី ជាមួយដូចថាក្រុមយើងលាងថ្មអីចឹងលេងសើចជាមួយគ្នាអត់អីទេ ។

ទ្រី: មីងកាលហ្នឹងបានធ្វើអនុប្រធានកងអីគេដែរមីង បានន័យថាប៉ុន្មាននាក់កងហ្នឹង?

គឿន: ម៉ាកងហ្នឹងវាមាន៣២នាក់ ។

ទ្រី: អីចឹងយើងប្រាប់កងយើងកូនចៅយើងថាម៉េចដែរទៅ?

គឿន: ប្រាប់ថាម៉េចទៅដល់ពេលម៉ោងធ្វើការងារអីចឹងនាំគ្នាទៅៗ ។

ទ្រី: មីងកាលហ្នឹងឡើងធ្វើអនុកងគេហ្នឹងឆ្នាំណា?

គឿន: ដឹងឆ្នាំប៉ុន្មានហើយទេ ភ្លេចហើយយូរដែលហើយ ។

ទ្រី: មីង! ប៉ុន្មានថ្ងៃប្រជុំម្ដងក្នុងកងមីងហ្នឹង? អស់... SideA....

# SideB

ទ្រី: ចុះយើងប្រជុំជាមួយមេធំៗទៀតប៉ុន្មានថ្ងៃទៅ?

គឿន: អត់ដែលបានទៅប្រជុំជាមួយគេផង គេទើបហ្នឹងឲ្យយើងធ្វើអីចឹងណា ហីដល់ហើយរត់បែកគ្នាបណ្ដោយ ។

ទ្រី: មីងកាលហ្នឹងបានធ្វើប្រធានរាងធ្ងរស្មើយបន្តិចដែរឬ?

គឿន: អត់ទេ! នៅកូនក្រុមក៏ដូចតែគ្នា វាអត់មានលំបាកអី អត់ដែលលំបាកអី កន្លែងពួកខ្ញុំអត់ដែរពិបាកអី ។

ទ្រី: អីចឹងអត់មានបញ្ហាអីទាំងអស់?

គឿន: អត់!

ទ្រី: អត់មានអ្នកណាយកទៅណា ធ្វើបាបសម្លាប់កាប់ចាក់អីអត់?

ភឿនៈ អត់! និយាយទៅរោងចក្រហ្នឹងអត់មានបញ្ហាស្លាប់រស់អីរឿងស៊ីចុកអីអត់ ស្រួលម្យ៉ាងដែរ ។

ទ្រីៈ មីង! អាការយកស្រីៗចេញពីផ្ទះកុំធ្វើការងារក្នុងចិញ្ចឹមកូន ដាំបាយអីជាការងារល្អអីដែរ ឬមួយក៏ម៉េចខ្មែរធ្វើយកមីងទៅអីចឹងដើម្បីកុំឲ្យមីងធ្វើការផ្ទះច្រើនពេកអីចឹង មីងគិតថាម៉េចដែរការងារហ្នឹង?

ភឿនៈ ដឹងល្អអីបើគេអត់ឲ្យយើងនៅជាមួយម៉ែឪ គេឲ្យយើងទៅហើយចេះតែទៅហើយ ។

ទ្រីៈ អីចឹងគេមិនមែនធ្វើអីចឹងល្អសម្រាប់ស្ត្រីយើងទេ អីចុង គេថាធ្វើអីចឹងល្អ នយោបាយថាធ្វើអីចឹងបានល្អ តាមពិមីងផ្ទាល់យល់ថាម៉េចដែរ?

ភឿនៈ ខ្ញុំយលថាអត់ល្អ ព្រោះខ្ញុំបែកពីម៉ែឪ ព្រោះគេម៉ែឪហ្នឹងបានតិចៗរត់មកផ្ទះ ។

ទ្រីៈ មីង! អាការដែលមីងទៅរស់នៅភ្នំពេញ ធ្វើរោងចក្រធ្វើអីតិចតួចការងារហូបចុក៣ថ្ងៃបន្ថែមម៉ាងដងអីចឹង មីងគិតថាពីមុនហីឥឡូវ ថ្ងៃនេះ អាណាស្រួលជាង?

ភឿនៈ បន្ថែម៣ថ្ងៃម្តងហ្នុងអីចេះ...

ទ្រីៈ មីង! ខ្ញុំចង់និយាយថាជីវិតមីងកាលពីនៅភ្នំពេញណា ហីនិងឥឡូវនេះសព្វថ្ងៃនេះណាស្រួលជាងពីរហ្នឹង?

ភឿនៈ ឥឡូវវាស្រួលហើយ យើងហូបហីស្មើណាក៏បាន ។

ទ្រីៈ ហេតុអី?

ភឿនៈ ឥឡូវស្រួលណាស់យើងចង់ហូបស្មើណាក៏បាន ហីកាលហ្នុងគេឲ្យយើងហូបបន្ថែម៣ថ្ងៃមួយហ្នុងមកពីយើងផ្តល់ឈាមឲ្យគេណា បានគេឲ្យហូបបំប៉នឈាមយើងឲ្យយើងមានឈាមស្រួលគេយកឈាមយើងទៀត ហើយហ្នឹងកុំតែយើងរត់ទាន់ហ្នឹងណា រត់មិនទាន់ដឹងយកប៉ុន្មានសារគ្រាន់តែរួច២ដង បូមឈាមពីរដងហើយ ស្នាមបូមឡើងប្រហោងក្រហូបូមម៉ាដងម៉ាកំប៉ោកប៉ុននេះ បូមលើកទី១អត់អីទេ បូមលើកទី២ ដើរមកវិលមុខម៉ង ។

ទ្រីៈ មីងដំបូងមីងប្រាប់ថា ខ្មែរក្រហមប្រាប់ថាគេចង់ជួយប្រជាជនយើងក្រីក្រអីរស់នៅឲ្យផុតពីការជិះជាន់ណា ដល់ពេលក្រោយមកទៀត មីងគិតថាក្រោយមកទៀតខ្មែរក្រហមធ្វើចង់រំដោះប្រជាជនយើងមែន ឬមួយក៏លែងចង់រំដោះជួយអ្នកក្រអី ក្រោយមកទៀតគិតម៉េចដែល?

ភឿនៈ ក្រោយមកទៀតមិនបានគិតអីដែរ បើក្រោយមកទៀតខ្ញុំអត់នៅហ្នឹងផង ក្រោយទៀត កាលហ្នឹងម៉ាជិនាន់ហ្នុងគេមិនឲ្យយួនចូលស្រុក ដល់ហើយ៧៩ យើងមិនរត់ ៧៩ ខែ១ ថ្ងៃទី៧ យើងមិនរត់ រត់ចេញពីកន្លែង រត់ចេញវាបែកគ្នាអស់ទៅខ្លះទៅណេះ ខ្លះទៅណុះ អស់ទៅ ទៅដោយខ្លួនទៅ ។

ទ្រី: អីចឹងមីងពេលដែលមីងរត់ទៅលិចហើយ តើសប្ដ?

ភឿនៈ ចាំ!

ទ្រី: មីងគិតថាមានដឹងថាខ្មែរក្រហមអាក្រក់អីដែរ នៅតែល្អដដែល នៅតែជួយអ្នកក្រដដែល?

ភឿនៈ អត់ដឹងថាគេអាក្រក់ល្អគ្រាន់តែទៅ យើងទៅនៅជាមួយប្រជាជន ដើរសុំប្រជាជននៅ ជាមួយអីចឹងទៅ ។

ទ្រី: អីចឹងខ្មែរក្រហមវាមិនជាធ្វើបាបប្រជាជនទេមីង?

ភឿនៈ ខ្ញុំអត់ដែរជួបប្រទះដែរ បើកន្លែងផ្សេងមិនដឹង បើកន្លែងខ្ញុំ ។

ទ្រី: មីងពេលនៅភ្នំពេញហ្នុងយើងធ្វើជាក្រុមផ្សេងៗជាមួយប្រុសឬក្រុមជាមួយគ្នាដែរម្ដង?

ភឿនៈ ប្រុសនៅផ្សេងទៅ ស្រីនៅផ្សេងទៅប៉ុនគ្រាន់ថា ដល់ពេលយើងធ្វើការងារដូចថា យើង ចាក់បេតុង ចាក់ជាសរសរ ប្រុសៗគេវៃពុម្ពណា ហើយយើងលាយ...ចាក់ទៅ គេ សម្រាប់តែវៃពុម្ព ក្រុមខុសគ្នា ប៉ុនពេលធ្វើការងារជាមួយគ្នា ។

ទ្រី: អីចឹងនៅក្រុមមីង៣០ នាក់សុទ្ធស្រីអីចុង?

ភឿនៈ ស្រី! ក្នុង៣០ នាក់ហ្នឹង៣ក្រុមទៀតណា ក្នុងម៉ាក្រុម១០ នាក់ ។

ទ្រី: អីចឹងស្រីហ៊ីប្រុសអត់មាននៅជាមួយគ្នាទេ ឬក៏នៅជាមួយគ្នា?

ភឿនៈ អត់មាននៅជាមួយគ្នាទេ ផ្ទះគេនៅផ្សេង យើងនៅផ្សេង ប៉ុនដល់ពេលចេញធ្វើការងារ ចេញជាមួយគ្នា សហការគ្នា ។

ទ្រី: អត់មានបង្ខំឲ្យមីងមីងរៀនការរៀបអីពេលហ្នុង?

ភឿនៈ កាលហ្នឹងបង្ខំ ។

ទ្រី: មីងមាន....ថាខ្មែរក្រហមបង្ខំឲ្យមីងរៀបការទេពេលហ្នុង?

ភឿនៈ កាលហ្នុងគេឲ្យរៀបការហ្នុងគេឲ្យចាប់ដៃគ្នាក្នុងម៉ាសារពាគូរ ។

ទ្រី: មីងណា គេបង្ខំឲ្យមីងរៀបការដែរពេលហ្នុង?

ភឿនៈ ចាំ!

ទ្រី៖ ការបង្ខំឲ្យរៀបការហ្នឹងគិតថាម៉េចដែរ ល្អទេការរៀបការបង្ខំ?

ភឿន៖ វាម៉េចល្អបើយើងអត់មាននៅបន្ទុកគ្រួសារនៅក្នុងម៉ែឪយើងទុកដាក់ណា ប៉ុនបើគេចាប់ឲ្យយើងរៀបអីចឹងទៅ បើយើងមិនធ្វើតាមគេ ខ្លាចគេធ្វើបាប ។

ទ្រី៖ អីចឹងអ្នកណាគេអ្នករើសប្ដីឲ្យមីងពេលហ្នឹង?

ភឿន៖ ចាំ!

ទ្រី៖ អ្នកណាអ្នករើសគ្រួសារឲ្យមីង?

ភឿន៖ គេនៅឆ្ងាយអត់ស្គាល់ទេ នៅរោងចក្រណុះ ។

ទ្រី៖ មីងមានបដិសេធប្រកែកប្រណាំងអីទេ?

ភឿន៖ ប្រកែកប្រណាំងក៏ប្រកែកមិនបាន បើគេចាត់តាំងយើងឲ្យយើងមានគ្រួសារហើយ ។

ទ្រី៖ មីងអាយុប៉ុន្មានកាលហ្នឹងមីងរៀបការ?

ភឿន៖ ៧៨ហើយជិតចូល៧៩ហើយហ្នឹង ជិតរត់ហើយហ្នឹង រៀបការហើយបាន៣ខែរត់ទៅ នៅជាមួយគ្នាបាន...រត់បែកគ្នារហូត ។

ទ្រី៖ អីចឹងពេលការហើយយើងអាចនៅជាមួយគ្នាអាចទំនាក់ទំនងទៅមកសួរសុខទុកអីបាន?

ភឿន៖ អត់! ព្រោះអីរៀបហើយបានប៉ុន្មានថ្ងៃរត់ហ្នឹង មានបានជុំគ្នាណាអត់បាននៅជាមួយគ្នាផងហ្នឹង ផ្សេង១ទៅ ។

ទ្រី៖ មីង! ការហើយឲ្យប្ដីប្រពន្ធរស់នៅផ្សេងពីគ្នា មីងយល់ឃើញអាម៉េចដែល?

ភឿន៖ ដឹងម៉េចទេ រៀបហើយរត់ម៉េចបាននៅជាមួយគ្នា បើរត់បែកគ្នា រត់ផ្សេង១គ្នាទៅផ្សេង ។

ទ្រី៖ អីចឹងយើងចង់ធ្វើប្ដីប្រពន្ធគ្នាដែរ ប៉ុន្តែគេអត់ឲ្យនៅជាមួយទេ?

ភឿន៖ អត់មានបាននៅជាមួយគ្នាមកពីអីចេះ មកពីយើងរត់បែកគ្នាណា រៀបហើយយើងរត់បែកគ្នាណា គេទៅផ្សេងយើងទៅផ្សេងណា ។

ទ្រី៖ លែងបានជួបរហូត?

ភឿន៖ ដល់មកជួបគ្នា ឈឺរឿងខ្លួន ដល់ឈឺទៅឈឺស្លាប់ទៅ ។

ទ្រី៖ ពួក១៧មេសាមីងគិតម៉េចដែរ?

ភឿន៖ ខ្ញុំអត់សូវដឹងដែរ ព្រោះអី១៧មេសាគេមកណេះមក ខ្ញុំទៅណុះអត់សូវដឹងដែរ ។

ទ្រី៖ ពេលប្រជុំអត់មាននិយាយពីពួក១៧មេសាអីទេ?

ភឿន៖ អត់! គេមិនសូវលើករឿងអីផង គេច្រើនតែលើកឲ្យយើងប្រឹងធ្វើការងារទៅ ។

ទ្រី៖ មីងកាលហ្នឹងធ្វើប្រវត្តិរូបទេ?

ភឿន៖ ដូចអត់ដឹង ភ្លេចហើយ ហីគាត់យកប្រវត្តិរូបហ្នឹងពីកន្លែងណា?

ទ្រី៖ យកមកពី....កសិកម្ម ។

ភឿន៖ ធ្វើប្រវត្តិរូបហ្នុងយូហើយ មិនដឹងជាធ្វើឆ្នាំណាខែណា...

ទ្រី៖ អរគុណមីង!

ទ្រី: បានអីចឹងមែនឬ?

ខន: ហ្ហ! បើថាឲ្យស្រីទៅលីបាវអាណាលីរួច បើប្រុសលីរួចស្រីណាលីរួច បើបាវស្រូវមាំបាវពេញនោះ គេលីរួចខ្ញុំលីអត់រួចទេ ព្រោះខ្ញុំអត់ខ្លាំងអាណាលីរួច ។

ទ្រី: តើគេមានប្រាប់មីងថា អូ! សិទ្ធិនារីសិទ្ធិបុរសអី គោរពសិទ្ធិគ្នាស្មើគ្នា?

ខន: គេនិយាយប្រាប់អីចឹង ថាយើងបុរស និងស្ត្រីសិទ្ធិស្មើគ្នា គេសម្រេចការងារបានយើងក៏សម្រេចបានដែរ ហ្នឹងគេលើកឡើងអីចឹងម៉ង គឺធ្វើអ្វីបានដូចតែគ្នា ។

ទ្រី: កាលជំនាន់ខ្មែរក្រហមស្រីហ៊ីប្រុសសិទ្ធិស្មើរអីចឹងមែនឬ?

ខន: ហ្ហ! គេលើកឡើងបំពាប់អីចឹង ហ៊ីជាយោបល់ លោកពូខ្ញុំឆ្ងល់ដែលអត់ បើឲ្យស្រីលីដូចខ្ញុំថាហ្នឹងវារួចដែរអត់ គ្រាន់តែយោបល់វាចេះតែមានសិទ្ធិនិយាយដូចគ្នា ។

ទ្រី: មីងមានដែលឮពាក្យថា បដិវត្តខ្មែរក្រហមណា យកចិត្តទុកដាក់ជាមួយនារីណាស់ ព្រោះថាពេលរំដោះហើយក្លាមហ្នឹងមិនឲ្យនារីនៅផ្ទះធ្វើការផ្ទះដុចពីមុនគេទៀតទេ យកនារីចេញៗក្រៅ ធ្វើការមានដែលឮការនិយាយរៀបរាប់បែបហ្នឹងទេ?

ខន: អត់...។

ទ្រី: មីងអាការឲ្យស្រីៗយើងចេញក្រៅពីផ្ទះ ទៅធ្វើការឆ្ងាយពីផ្ទះអីចឹងណា មីងយល់ថាអាហ្នឹងល្អឬក៏អាក្រក់?

ខន: ចេញធ្វើការមានអី តែខ្ញុំអត់យល់ព្រោះខ្ញុំដូចជាអត់ស្តាប់....

ទ្រី: ខ្មែរក្រហមវាឲ្យស្រីៗចេញពីផ្ទះទៅធ្វើការឆ្ងាយៗដូចមីងអីចឹង?

ខន: ទៅធ្វើស្រែចម្ការអីចឹង?

ទ្រី: ទៅធ្វើតាមក្រសួងបម្រើឆ្ងាយៗអីផ្ទះណា អត់ឲ្យនៅក្នុងផ្ទះធ្វើស្រែធ្វើចម្ការដាំបាយទៀតទេ អីចឹងមីងយល់ថាធ្វើអីចឹងល្អអត់ វាល្អដែរ ឬមួយក៏វា...។

ខន: ដូចអត់យល់ម៉ងមិនដឹងជាយ៉ាងម៉េច អត់យល់ខ្លួនឯងទាល់សព្វថ្ងៃដែរ ។

ទ្រី: មីងយល់ថាវាល្អទេ វាធ្វើអីចឹង ជួនកាលល្អដែរណាគេឲ្យយើង...?

ខន: យើងចេះតែទៅធ្វើអីចឹង យើងទៅធ្វើជួនបានជលនេះដឹងតែយកមកហូប តែអប់រំនារីបានល្អអត់មានស្រីប្រុសស្រឡាញ់គ្នាបានណា អត់មានសិទ្ធិឲ្យយើងស្រឡាញ់គ្នាព្រៃផ្សៃបានទេ របបហ្នឹង ។

ទ្រី: អីចឹងមីងសប្បាយចិត្តនឹងទំនាក់ទំនងហ្នឹងឬ?

ខនៈ ចា៎! ការហារអត់ឲ្យស្រីស្រឡាញ់ប្រុស ទាក់ទងសេរីតាមចិត្តទេ ។

ទ្រីៈ ម៉េចអីចឹងមីង?

ខនៈ បើយើង បើថាគ្រួសារចង់បានអីចឹង អាហ្នឹងគេរៀបឲ្យអីចឹងម៉ង ចា៎!

ទ្រី អីចឹងមីងអត់បានរៀបការនៅជំនាន់ហ្នឹងទេ?

ខនៈ ខ្ញុំរៀបនៅភ្នំពេញនេះ ។

ទ្រីៈ ឆ្នាំណា?

ខនៈ ចុងឆ្នាំ៧៧ហើយ ។

ទ្រីៈ អីចឹងមីងរើសខ្លួនឯង?

ខនៈ អត់ទេ! គេរៀបម៉ង ។

ទ្រីៈ អីចឹងមីងអត់យល់ទាស ជំទាសអីទេ?

ខនៈ ម៉េចហានជំទាស បើខ្លាចគេដកយកចេញ ខ្លាចគេចាប់ ។

ទ្រីៈ អីចឹង គ្រួសារមីងនៅទេ?

ខនៈ គ្រួសារខ្ញុំអត់នៅជង ។

ទ្រីៈ អីចឹងបានន័យថាមីងព្រមដែរ?

ខនៈ ចា៎! ចុះខ្លាច មុនរៀបហ្នឹងគេសួរ សួរហើយគេថាអីចឹងយើងអត់គោរពតាមការចាត់តាំង ។

ទ្រីៈ អីចឹងយើងអត់មានសិទ្ធិប្រកែកទេអីចឹង?

ខនៈ អត់! ប្រកែកអី ប្រកែកខ្លាចគេថា យើងអត់គោរពតាមការចាត់តាំងចា៎! អីចឹងគេដក់ចេញហើយ ។

ទ្រីៈ មីងថាទំនាក់ទំនងស្រីហីប្រុសហាមឃាត់អីចឹងល្អ ចុះអាការឲ្យស្រីៗចេញក្រៅភូមិអាហ្នឹងល្អឬអាក្រក់?

ខនៈ ដឹងយ៉ាងម៉េចដែរ មិនយល់ដែរ បើចេញយើងការពារខ្លួនបានមានអី ខ្លាចតែមិនមែន ។

ទ្រីៈ អីចឹងមីងខ្លួនឯងវិញម៉េចដែលសប្បាយចិត្តទេ?

ខនៈ ខ្ញុំចេញមកអន្តភាពជុំគ្នាអីចឹង វាដូចថានឹកក្នុងចិត្តអីចេះទេ បើមិនចេញក៏នៅតែថ្ងៃក្រោយជៀសគេហៅមកមិនរួច អីចឹងទល់តែទៅ ។

ទ្រី: មីងកាលពីមីងនៅធ្វើការជាមួយខ្មែរក្រហមហ្នឹង មីងអាហ្នឹងការងារហ្នឹងប្រុសផ្សេងៗស្រីផ្សេងឬ តាមក្រុមវាឬក៏យ៉ាងម៉េច?

ខន: ចាំ! ទៅតាមក្រុម ក្រុមស្រីផ្សេងប្រុសផ្សេង ។

ទ្រី: មីងអត់មានត្រូវខ្មែរក្រហមធ្វើបាបទារុណកម្មអីទេ?

ខន: អត់...

ទ្រី: មីងអត់ដែលមាន ឬក៏ឮអីការអានទង់បដិវត្តខ្មែរក្រហមនយោបាយអីចេះអីចុះអីទេមានដែលឃើញមានដែលអានអីទេ ។

ខន: គ្រាន់តែគេលើកបង្រៀអារឿងដូចថាយើងវ៉ៃចក្រពត្តិអារិកហ្នឹងណា គ្រាន់ថារំដោះអីចឹងទៅណា ប៉ុនរឿងទង់អី ខ្ញុំមិនដឹងព្រោះខ្ញុំអត់សូវបានរៀនទេ ខ្ញុំនៅសម័យនោះខ្ញុំអត់សូវបានរៀនទេ ។

ទ្រី: មីងមានដែលសាប់វិទ្យុខ្មែរក្រហមអីទេកាលហ្នុង...?

ខន: អត់មានវិទ្យុស្តាប់ទេ នៅក្នុងនេះអីចឹងនោះ នៅក្នុងក្រុមអីចឹង ។

ទ្រី: មីងមានបានពួកខ្មែរក្រហមបង្ហាបឲ្យរៀនថាអូ!ពួកណា នេះយើងត្រូវស្រែកអីចេះចម្រៀងនេះយើងត្រូវច្រៀងអីចេះ?

ខន: អត់ទេឮតែចម្រៀងគេចាក់ពេលព្រឹកម៉ោង៦,៧គេមិនចាក់ចំរៀង ។

ខន: មីងអត់ចេះច្រៀងទេអីចុង ឮតែចម្រៀងចាក់ ខ្ញុំគ្រាន់តែស្តាប់អីចឹង ។

ទ្រី: ពិរោះដែរមីង?

ខន: ចាំ! ហ្អបើដូចសម័យហ្នុងវាអត់មានសម័យអីទៀតទេដឹងតែមួយអីចឹងទៅ វាចេះតែស្តាប់ទៅ ។

ទ្រី: មីងកាលហ្នឹងគេច្រៀងពីអីខ្លះ?

ខន: គេច្រៀងពីទង់ក្រហមបដិវត្តបកអីចឹងទៅណា រំដោះ១៧មេសា អីចឹងទៅណា ។

ទ្រី: មីងគិតថាចំរៀងហ្នឹងពិរោះ...?

ខន: ដូចថាថ្ងៃ១៧មេសារំដោះ ហើយអីចឹងចេះតែស្តាប់ទៅ...អស់ SideA........

SideB

ទ្រី: មីងពេលទៅធ្វើការក្នុងស្រែក្នុងចម្ការឆ្ងាយៗ អត់មានបានច្រៀងបានអីទេ?

ខន: អត់ទេ!

ទ្រី: មីងរបបខ្មែរក្រហមមីងបានមានអារម្មណ៍ថា មុនដំបូងចូលចិត្តដែរ ដល់ក្រោយមកអត់ចូលចិត្តវិញ ដោយសារអីចេះអីចុះអី មីងចាប់អារម្មណ៍អីចឹងទេ?

ខន: អត់មានចាប់អារម្មណ៍ ព្រោះដូចនៅស្ទើពេក អត់ដឹងនយោបាយយ៉ាងម៉េចទេ វាអត់ដឹងអីចឹងម៉ងនិយាយឲ្យចំដូច...ដូចស្ទើរដូចក្មេងយើងអីចឹងណា តែនៅក្នុងរបបណាគ្មានទៅគិតឃើញរឿងរបបថ្មីណាទៀត អត់ដឹងផង ។

ទ្រី: អីចឹងទេដែលយើងធ្វើការឲ្យអង្គការហ្នឹងយើងមានអារម្មណ៍សប្បាយរីករាយ?

ខន: ចា៎! ចេះតែសប្បាយទាំងអស់គ្នាហ្នឹង អ្នកធ្វើដូចគ្នាហ្នឹងចេះតែសប្បាយអីចឹង គ្មានអាណានឹកគិតរឿងអីដឹងតែពីធ្វើ ។

ទ្រី: ចុះដល់ក្រោយមកដល់ឆ្នាំ៧៥ ១៧មេសាការងាររមីង ដោះដូរធូរស្រាលវិញឬយ៉ាងម៉េច?

ខន: ១៧ មេសាអាហ្នឹង...

ទ្រី: ៧៥ណា?

ខន: កាលយើងរំដោះហើយ...

ទ្រី: ខ្មែរក្រហមចូលភ្នំពេញ?

ខន: កាលខ្មែរក្រហមចូលភ្នំពេញហ្នឹងឬ?

ទ្រី: បាទ! បានធូរស្រាលជាមុនបន្តិច ឬក៏យ៉ាងម៉េច?

ខន: ខ្មែរក្រហមចូលភ្នំពេញយើងដែលខ្ញុំថា ខ្ញុំនៅភ្នំពេញហ្នឹង នៅធ្វើរោងចក្រហ្នឹង កសាងរោងចក្រហ្នឹង ធ្វើថ្មីហ្នឹង ។

ទ្រី: មីងជួយធ្វើរោងចក្ររោងអីដែរ?

ខន: ជួយ! ចុះគេប្រើឲ្យលាយអីម៉ងបូក ចាក់គ្រឹះ ចា៎អីចឹង ។

ទ្រី: រោងចក្រអីមីង?

ខន: បឹងស្រយ៉ាបហ្នឹង រោងចក្រក្រឡឹងនៅបឹងស្រយ៉ាបយើងឯលិចពោធិ៍ចិនតុងហ្នឹង ។

ទ្រី: រោងចក្រហ្នឹងរោងចក្រធ្វើអី?

ខនៈ	ពេលក្រឡឹងដែលខ្ញុំនិយាយថា	គេទើបចក្រកសាងហើយចាក់ម៉ាស៊ីន	ចាក់ដើងម៉ាស៊ីន ហ្នឹង ។

ទ្រីៈ	អាហ្នឹងពេលចរកក្រឡឹងហ្នឹងស្រឡឹងធ្វើអីគេមីង?

ខនៈ	ក្រឡឹងដែក ដូចថាយើងក្រឡឹងទឹងអីចឹងឡានអីចឹងទៅណា ក្រឡឹងរបស់ចាស់ៗអីចឹងទៅ យើងត្រូវផ្លាស់ឡានហ្នឹង ហ្នឹងពេលចក្រគេកសាង... ។

ទ្រីៈ	អាហ្នឹងចាស់ៗធ្វើឲ្យថ្មីឬ?

ខនៈ	ដូចថាយើងត្រូវក្នុងម៉ាស៊ីអីចឹងណា សំលៀងអាស៊ីក្នុងម៉ាស៊ីន អីចឹងណាអាស៊ីក្នុងដោះម៉ាស៊ីនស៊ីហ្នឹង គឺពេលចក្រគេធ្វើ ដាក់ម៉ាស៊ីនអស់ហ្នឹងដើម្បីសំលៀងធ្វើកសិកម្មណា អាដូចរបស់ឡានយើងចាស់ហើយយើងវាមិនខូច ខូចប៊ីសស្តុងមួយ យើងមិនយកប៊ីសស្តុងថ្មីមកក្រឡឹង ក្រឡឹងយកទៅដាក់ឡានចាស់ហ្នឹងវិញ ជួសជុលម៉ាស៊ីនណា ។

ទ្រីៈ	មីង! ក្រៅពីជួយធ្វើអាគាពេលចក្រហ្នឹង ធ្វើអីផ្សេងទៀត?

ខនៈ	កាលនៅសង្គមនិយមអីចឹងហើយក្នុងម៉ាអាទិត្យអីចឹងទៅស្ទូងស្រូវអីចឹងម៉ាថ្ងៃពីរថ្ងៃអីចឹងទៅ ។

ទ្រីៈ	អាហ្នឹងធ្វើនៅភ្នំពេញដែលឬយ៉ាងម៉េច?

ខនៈ	ចា៎! ធ្វើនៅភ្នំពេញ ។

ទ្រីៈ	មីងកាលហ្នឹងថាធ្វើអនុប្រធានកងអនុសេតូចកសិដ្ឋានសំពៅពូន អាហ្នឹងមានន័យថាម៉េចអានុប្រធានកងអនុសេនាតូចហ្នឹង ។

ខនៈ	កាលហ្នឹងកាលពីសម័យ...

ទ្រីៈ	កសិដ្ឋានអគ្គរជ័យឬ?

ខនៈ	កសិកម្មអគ្គជ័យ ។

ទ្រីៈ	អនុសេនាតូចកសិដ្ឋាន...?

ខនៈ	មើលឲ្យអស់មើលថាអាម៉េច?

ទ្រីៈ	អនុប្រធានកងអនុសេនាតូចកសិដ្ឋាន អាហ្នឹងម៉េចដែរ?

ខនៈ	អាហ្នឹងដូចថាយើងកាន់ ដូចថាគេម៉ាកងអីចឹង ក្នុងម៉ាភកងវាមានគ្នា៣០នាក់អីចឹងវាមានប្រធានមួយ វាមានអនុមួយ បើសិនជាប្រធានអត់នៅវាមានអនុ គេអ្នកចាត់ចែងការងារ ។

ទ្រី: អីចឹងមីងធ្វើប្រធាន៣០នាក់ហ្នឹង?

ខន: ខ្ញុំអត់ប្រធានទេ មានគេលើខ្ញុំ ។

ទ្រី: ប៉ុន្មាននាក់ ៣០អីចឹង?

ខន: ចាំ!

ទ្រី: អីចឹងយើងមានបានបង្រៀនបំពាក់បំប៉នយោបាយពួក៣០នាក់ហ្នឹងក្រោមយើងទេ?

ខន: ដូចថាបើសិនជាប្រជុំអាហ្នឹង ក៏គេប្រជុំអីចឹងណា ប្រជុំពេលល្ងាចអីចឹង ដូចថានិយាយពីយើងធ្វើការក្នុងមួយថ្ងៃហ្នឹងណា ដូចថាយើងធ្វើបានអ៊ីខ្លះ ល្ងាចឡើងយើងនិយាយទៅ យើងធ្វើទៅដូចខាតរបស់នេះមួយ ខូចរបស់នេះមួយ អាហ្នឹងយើងរាយការណ៍តាមហ្នឹង អីចឹងណា គឺអីចឹងម៉ងហ្នុង ។

ទ្រី: ចង់និយាយពីផលពិបាក ផលល្អអីចឹងទៅសមាជិកយើង?

ខន: ចាំ! ដូចថាយើងធ្វើស្រែអីចឹងទៅ ទៅធ្វើក្នុងមួយថ្ងៃបានប៉ុន្មាននាក់អីចឹងទៅ អីដូចថាគេឲ្យធ្វើក្នុងមួយថ្ងៃអីចឹងយើងធ្វើឲ្យហើយក្នុងស្រែមួយអីចឹងៗណា ហីយើងធ្វើអត់ហើយទេ បានតែពាក់កណ្តាលអីចឹងរាយការណ៍អីចឹងទៀតទៅណា ថាធ្វើមិនហើយអីចឹងទៅមូលហេតុអី ។

ទ្រី: អីចឹងមានអ្នកខ្ជិលអ្នកប្រហូសទេក្នុងកងមីង?

ខន: វាមានអ្នឈឺអីចឹងទៅ ដូចថាឈឺអីចឹងហ្នឹងដេកទៅ អ្នកឈឺនៅកន្លែងអីចឹងទៅ ពេទ្យគេព្យាលបាលទៅ ។

ទ្រី: ចុះមានខ្មាំងបង្កប់អីនៅក្រុមយើងទេ?

ខន: អត់ដែរ ព្រោះគ្នា៣០នាក់ជាងដូចអត់មានអ្នកណាអីដែរ ព្រោះនារីសុទ្ធតែទៅពីស្រុកអីចឹង?

ទ្រី: ចុះអត់មានពួក១៧មេសានៅក្នុងហ្នឹងទេអ៊ីចុង?

ខន: អត់ទេ! ពួក១៧មេសា ពេលក្រោយមកទៀត កាលនៅអន្លង់ជ័យអាហ្នឹងបានមាននិស្សិតមកពីបរទេសណា ហ្នឹងគេចុះទៅធ្វើការអីចឹងទៅ ចុះធ្វើជាមួយទៅ ប៉ុននិស្សិតស្រុកខ្មែរទេណាដែលទៅរៀនប្រទេសគេណា ។

ទ្រី: អាហ្នឹងនៅអន្លង់ជ័យឆ្នាំណា?

ខន: កាលវីរំដោះបាននៅឆ្នាំ៧៥ ឆ្នាំ៧៦,៧៧នៅអន្លង់ជ័យហ្នឹង ។

ទ្រី: ចុះជាមួយពួកនិស្សិតហ្នឹងមីងធ្វើម៉េចទៅ?

ខនៈ ជាមួយពួកនិស្សិតចេះតែធ្វើការទាំងអស់គ្នាទៅ គាត់ក៏ស្ទូវ យើងក៏ស្ទូងស្រូវ ។

ទ្រី: អត់មានការ វ៉ៃធ្វើបាបអីខ្លាំង?

ខនៈ អត់ដល់ក្រោយមកបែកគ្នាទៀតមិនដឹងទៅណា អត់ដឹងដែរ ។

ទ្រី: មីងកាលហ្នឹងបានធ្វើអនុប្រធានកងអីចឹងយើង ចំណុចល្អស្អី ហើចំណុចអាក្រក់ស្អី បើយើងធ្វើប្រធានអីចឹង?

ខនៈ ចំណុចល្អគ្រានាអប់រំគេហ្នឹងណា អប់រំឲ្យល្អដើរតាមមាគ៌ាតែអីចឹងដូចថា យើងតាំងខ្លួនយើងឲ្យបានល្អកុំមានការទាក់ទងហើធ្វើការ កុំខ្ជិលរយើករយាកហ្នឹងណា ដូចថាដឹងតែពីប្រយុទ្ធធ្វើការងារ ។

ទ្រី: តើមីងមានបានជួយរាយការណ៍ពីអាណាខ្ជិលអាណាអីទៅប្រធានអត់?

ខនៈ អូ! អត់ ម៉ាកងខ្ញុំនៅអីចឹងគ្មានអាណាខ្ជិលមានតែអ្នកឈឺដឹងតែរាយការណ៍ឈឺអីចឹងម៉ង ។

ទ្រី: អីចឹងកាលហ្នឹងមីងធ្វើការដូចរាងងាយស្រួលដែរណ៎?

ខនៈ ចាំ! ព្រោះពួកខ្ញុំនិយាយគ្នាស្តាប់គ្នាបាន ចេះតែធ្វើអត់មានលំបាកចាំ ។

ទ្រី: មីងកាលហ្នុងហូបចុកគ្រប់គ្រាន់ដែរឬ?

ខនៈ ហូបកាលពីនៅភ្នំពេញអាហ្នឹងនៅអន្តជ័យ អាហ្នឹងគេដាំបាយកាត់ចែកគ្នា ដូចថាយើងម៉ាលីងសឹងអីចឹងណា ព្រោះអាហ្នឹងគេលើកឡើងពីខុះខាតយើងធ្វើស្រូវអត់បាន គេថាអីចឹងណា ។

ទ្រី: នៅភ្នំពេញគ្រាន់បើដែរ?

ខនៈ អាហ្នឹងនៅ អត់ទេ! ខ្ញុំនៅអន្តជ័យហ្នឹងម៉ង ដលចេញពីភ្នំពេញហ្នឹងទៅ ទៅនៅអន្តរជ័យហ្នឹងហើយ ។

ទ្រី: ចុះកាលនៅភ្នំពេញហូបគ្រប់គ្រាន់ទេ?

ខនៈ កាលនៅភ្នំពេញហូបចុកធម្មតាហូបនំប៉័ងហ្នឹងដំបូង... ។

ទ្រី: ហូបចុកហ្នុងគ្រប់គ្រាន់ទេមីង?

ខនៈ ចាំ!

ទ្រី: គ្រប់គ្រាន់ទេ?

ខនៈ ខុះខាតអីចឹងដែរ ប៉ុនដឹងធ្វើអាម៉េច ចេះតែហូបជាមួយសម្ងអីចឹងទៅនំប៉ុងហ្នឹង ក្រោយបាន បានបាយហូប ហើចុះមកធ្វើស្រែហ្នឹង បានបាយហូបម៉ង ។

ទ្រី: ហូបគ្រប់គ្រាន់ដែរទេហ្ន?

ខនៈ ចា៎! កាលនៅធ្វើស្រែហូប ពេលខ្វះខុះខាតដែរ ដល់ពេលដែលផលិតស្រូវអត់ទាន់បាន អីចឹង បាយគេដាំគាត់ចែកគ្នាហូបដែរតើ ពុះចែកគ្នាណា ដូចថាម៉ាដុំៗម្នាក់អីចឹងទៅលីងសីងមួយហ្នឹង ។

ទ្រី: មីងកាលហ្នឹងចេះតែប្រជុំៗ ប៉ុន្មានខែម៉ាម្ដងៗ?

ខនៈ ប្រជុំក្នុងម៉ាអាទិត្យអីចឹងប្រជុំម្ដង ។

ទ្រី: មីងពេលដែលយើងធ្វើការយើងធ្វើការម៉ាថ្ងៃប៉ុន្មានម៉ោង?

ខនៈ ធ្វើការពីម៉ោង៦ ម៉ោង៧ចូលធ្វើការទល់ម៉ោង១១សម្រាក់ ម៉ោង១ចូលវិញដល់ម៉ោង៥សម្រាក់ ។

ទ្រី: ៧,១១ ,១,៥?

ខនៈ ចា៎! ពីម៉ោង៧អីចឹងដល់ម៉ោង១១សម្រាក់ហើយណា ដល់ម៉ោងមួយបានចាប់ផ្ដើមធ្វើការវិញ ដល់ម៉ោង៥សម្រាក់ ហូបបាយ ។

ទ្រី: អត់មានធ្វើតទៀតពីម៉ោង៥ទៀតទេហ្ន?

ខនៈ ជួនយប់ដោយពេលទេ អត់មានរាល់ថ្ងៃទេណា ពេលណានេះទៅយប់ម្ដងម្កាលដែរ ។

ទ្រី: អីចឹងការងារដូចមិនធ្ងន់ធ្ងរណាស់ណាទេ?

ខនៈ ចុះការងារនៅកន្លែងហ្នឹងដូចថាមានអីធ្វើ ធ្វើតែស្រែហ្នឹង ដូចថាអ្នកជម្លៀសអីចឹងមានតែស្រែទេ ធ្វើនៅអង្គជ័យនោះ ។.

ទ្រី: មីងអាការងារនៅហ្នឹងរាងធូរស្រាលជាងអ្នកនៅតាមភូមិ?

ខនៈ ដឹងក្នុងភូមិម៉េចបើខ្ញុំអត់ដឹងក្នុងភូមិបើខ្ញុំទៅដុតអីចឹងហើយ ។

ទ្រី: មីងការងារហ្នឹងល្មមធ្វើបានដែរមិនជាតឹងស្រាលធូរអី?

ខនៈ ធ្វើតែស្រែ កាលមុនធ្វើធ្វើស្រែទល់តែយើងគាស់គល់វាំងក្នុងម៉ាថ្ងៃឲ្យបានពាគល់ម្នាក់អីចឹងទៅ ៤គល់ម្នាក់អីចឹង គឺតែប៉ុណ្ណឹង ។

ទ្រី: អត់មានធ្ងន...?

ខនៈ ចា៎! អត់មានធ្វើការងារអីខុសពីហ្នឹងផង នៅអន្លុងជ័យហ្នុងគេធ្វើតែអីចឹង ។

ទ្រី: ចង់និយាយថាការងារហ្នុងធ្ងន់ធ្ងរឬទេសម្រាប់មីង?

ខន: មិនធ្ងន់ទេធ្វើស្រែ ។

ទ្រី: អីណាប្រធានមីងឈ្មោះអីដែរ?

ខន: ខ្ញុំភ្លេចឈ្មោះគេហើយហ្នឹង ។

ទ្រី: មីងជួបប្រធានៗប៉ុន្មានថ្ងៃជួបម្ដង?

ខន: ប្រធានដែលគេហៅប្រជុំហ្នុងឬ ដូចថាកន្លះខែអីចឹងទៅ ឬក៏មាំខែអីចឹងទៅ ។

ទ្រី: ពេលមីងជួបមីងនិយាយពីការងារអីខ្លះ?

ខន: ចាំ! និយាយពីការងារដូចថាក្នុងមួយថ្ងៃ ក្នុងកន្លះខែហ្នឹងយើងធ្វើអីខ្លះ ខ្ញុំលើកឡើងអីចឹង ពីរឿងធ្វើស្រូវអីចឹងទៅ ។

ទ្រី: មីងអត់មានបាននិយាយ អត់មានបានព្រុណែនាំពីប្រធានយើង...មីង ការងារអី?

ខន: គ្រាន់តែណែនាំដូចថាចក្រពត្តិអាមេរិកអីចឹងទៅណាឈ្លានពាន ។

ទ្រី: អ្នកណាគេប្រាប់មីងអីចឹងហ្នឹង?

ខន: ប្រធានគេហ្នឹង គេចេះតែនិយមចុះយើងសម័យនោះមិនខ្លាចគ្រាប់បែក ដល់អីចឹងគេលើក ឡើងពីលទ្ធផលហ្នឹងឡើងទៅ ។

ទ្រី: ពេលក្រោយ៧៥ហើយ?

ខន: អាដែងនេះហើយហ្នឹងសម័យយើងខ្មែរក្រហមនេះ ។

ទ្រី: ចុះខ្មាំងរបស់ខ្មែរក្រហមអ្នកណាគេអីចុង?

ខន: ខ្ញុំមិនដឹងដែរ អ្នកណាក៏ធ្វើដូចតែគ្នា និយាយរួមទាំងអស់គ្នាក្នុងនេះ ។

ទ្រី: ប្រាប់យើងឲ្យប្រុងប្រយត្ន័ជាមួយខ្មាំង?

ខន: អីចឹងហើយខ្ញុំក៏ប្រាប់អីចឹងទៅ ថាការពារខ្លាចអីចឹងទៅ ។

ទ្រី: មីងមានបានយករឿងហ្នឹងប្រាប់កូនក្រុមយើងឲ្យប្រយត្ន័ប្រយែងទេ?

ខន: គ្រាន់តែប្រជុំប្រាប់អីចឹងយើងធ្វើការអីកុំខ្ជិលច្រអូសតែយើងធ្វើមិនស្អាតហ្នឹង គេថាយើងខ្លាច យើងខ្ជិលច្រអូសអីអាហ្នឹង គេខ្លាចយើងចូលដៃដើងអីចឹងទៅណា អាហ្នឹងគ្រាន់តែ ណែនាំពីលទ្ធផលធ្វើការងារហ្នឹង ។

ទ្រី: មីងមានបានជួយប្រាប់កូនក្រុមមីងថា មិនបាចចាំជួយគិតគូពីម៉ែឪនៅក្រោម នៅមូលដ្ឋាន ទេ គេល្អហើយ ។

ខនៈ អត់បាននិយាយពីរឿងឪពុកម្ដាយផង និយាយតែរឿងការងារខ្លួនឯងធ្វើ ។

ទ្រីៈ មីងមានដែរគិតមកដល់ផ្ទះសម្បែងម៉ែឪនៅសមរភូមិក្រោយនេះទេ?

ខនៈ បេះតែនឹកឃើញអីចឹងដែរ បើសិនជាមកងីចឹងជួបគាត់ ឃើញគាត់ហូបចុករួមដូចតែគ្នា អីចឹង មិនដឹងគិតម៉េច សើច...។

ទ្រីៈ មីងអត់មានបាននៅជាមួយគ្រួសារម៉ែឪអីចឹងមានអារម្មណ៍ម៉េចដែរ ឬក៏យើងត្រូវតែលាចាកដើម្បីបុព្វហេតុការពារបដិវត្ត...?

ខនៈ នឹងឃើញ អត់មាននឹកឃើញអីទេ ព្រោះនឹកឃើញបើគេចេញអស់ហើយ នឹកឃើញតែប៉ុណ្ណឹង នឹកឃើញចេញអស់ពីភូមិហើយ?

ទ្រីៈ អីចឹងធ្វើម៉េចត្រូវចាំបាច់អាហ្នឹងឬ?

ខនៈ ព្រោះគេលើកឡើងអីចឹងហើយ ដូចខ្ញុំប្រាប់ហ្នឹងថា គេត្រូវតែចេញអស់ពីភូមិមកធ្វើការងារប្រមូលផ្ដុំអីចឹងហើយ ហីម្ដាយឪពុកនៅក្រោយក៏ធ្វើសហករណ៍ ។

ទ្រីៈ ម៉េចបានគេអត់ឲ្យនៅស្រុកភូមិជាមួយម៉ែឪយើងធ្វើការជាមួយ?

ខនៈ អត់ដឹង ។

ទ្រីៈ មីងម៉េចបានខ្មែរក្រហមដួលរំលំ?

ខនៈ ដឹងអីអត់ដឹងដែរ សួរខ្ញុំ ឲ្យសួរអ្នកណាទៅ បើខ្ញុំមិនកាន់កាំភ្លើងផងហ្នឹងខ្ញុំម៉េចដឹង ។

ទ្រីៈ អីចឹងជំនាន់ខ្មែរក្រហមហ្នឹងមីងធ្វើជាម៉េចធ្វើការអីធ្ងន់ធ្ងរដែរ?

ខនៈ អត់សូវចាប់អារម្មណ៍ ដឹងតែធ្វើស្រែប៉ុណ្ណឹង ហីចម្ការដាំពោត ដាំស្រូវ...។

ទ្រីៈ ពេលវេលាអស់ហ្នឹងជាពេលវេលាដូចថាមីងធ្វើការងារធូរស្រាល...ឬក៏អត់ទេ?

ខនៈ ពេលវេលាអស់ហ្នឹងខ្ញុំយល់ថានៅផ្ទះក៏ធ្វើអីចឹង មកនេះក៏ធ្វើអីចឹង ទោះបីយើងមិនចេញវមក នៅចុះក៏គេឲ្យធ្វើអីចឹង ដូចតែគ្នា ។

ទ្រីៈ អីចឹងពេលហ្នឹងជាពេលសប្បាយមួយសម្រាប់មីង?

ខនៈ ចា៎! ទាំងអស់គ្នាអត់មានអាណាគិតឃើញអី ព្រោះជារួមក្នុងក្រុមគ្មានអាណាគិតនឹកឃើញអី ។

ទ្រីៈ មីងមានបានឮថាខ្មែរក្រហមចង់សម្លាប់ប្រជាជនខ្មែរអត់?

ខនៈ បេះតែឮថាខ្មែរក្រហមៗ ប៉ុនដឹងខ្មែរក្រហមមួយណា ដល់ហើយគេថាសុទ្ធតែគ្នាឯង សុទ្ធតែមនុស្សដូចតែគ្នាឯងហ្នឹងដដែលៗ ដល់អីចឹងមិនដឹងចាប់អារម្មណ៍លើអ្វី?

ទ្រី: អ៊ីចឹងមីងអត់ដឹងស្គាល់អ្នកណាជាខ្មែរក្រហមទេ?

ខន: អត់ដឹងអ្នកណាខ្មែរក្រហមណាអីបើខ្ញុំនៅចំណោមសុទ្ធតែនារីដូចតែគ្នាអីចឹងហ្នឹង ។

ទ្រី: អ៊ីចឹងកាលហ្នឹងមីងធ្វើអនុប្រធានហ្នុងធ្វើអនុប្រធានឲ្យ..?.

ខន: ក្នុងក្រុមហ្នឹងម៉ង ខ្ញុំដឹងនាំគ្នាធ្វើស្រែធ្វើចម្ការ ។

ទ្រី: ធ្វើឲ្យពួកណា?

ខន: នៅអន្លុរជ័យ យើងហ្នឹង... ។

ទ្រី: បាទ! ធ្វើឲ្យពួកណា?

ខន: ជ័យ ។

ទ្រី: ធ្វើឲ្យពួកណាទៅ?

ខន: ធ្វើឲ្យពួកអាជ័យហ្នឹង ។

ទ្រី: អាជ័យហ្នឹងអ្នកណាគេ?

ខន: ជ័យហ្នុងស្លាប់បាត់ហើយ ជ័យ សួនហ្នុង ។

ទ្រី: អ៊ីចឹងពួកជ័យ សួន ហ្នុងធ្វើការឲ្យក្រុមខាងណា?

ខន: អត់ដឹង!

ទ្រី: អ៊ីចឹងពួកណាដូចថាជាខាងគ្នាយើងជាមួយ វៃពួកណា គាំទ្រឲ្យពួកណា អ្នកប្រឆាំងជាមួយ អង្គការ គេមានប្រាប់មីងដឹងចឹងទេ ថាអូ! អ្នកនេះគេជួយយើង អ្នកនេះមិនមែនជួយ យើងទេ?

ខន: អត់មានដឹងថាអង្គការណាអង្គការណាផង អត់ដឹង ។

ទ្រី: មីងកាលហ្នឹងអាគេធ្វើប្រវត្តិរូបហ្នឹងមីងមានចាប់អារម្មណ៍ថាគេធ្វើប្រវត្តិរូបហ្នឹង?

ខន: ចាំ! ខ្ញុំចាប់អារម្មណ៍ដឹងថាគេឲ្យ ព្រោះយើងតែធ្វើការសារភាពថ្ងៃអីចឹងដល់នោះទៅគេហៅ រៀនម្តងៗ គេឲ្យធ្វើប្រវត្តិរូបយើងហ្នឹង គេឲ្យយើងសរសេរប្រវត្តិរូបហ្នឹងទៅ ចាំខ្ញុំសរ សេរទៅ ។

ទ្រី: ឆ្នាំណា?

ខន: សរសេរដូចឆ្នាំរំដោះហើយក្លាមហ្នឹង មិនទៅនៅអន្លុរជ័យហ្នឹង ដល់អីចឹងគេឲ្យធ្វើប្រវត្តិរូប អីចឹងចាំ ។

ទ្រី: មីងមកនៅកោះធំឆ្នាំណា?

ខនៈ ចាំ!

ទ្រីៈ មីងមកនៅខាងកោះធំឆ្នាំណា?

ខនៈ នេះឬ? ខ្ញុំនៅជិរំបានខ្ញុំចេញមកនៅណោះវិញ ។

ទ្រីៈ មីងកាលហ្នឹង មីងទៅនៅជិរំប៉ុន្មានឆ្នាំ?

ខនៈ ខ្ញុំរត់កាលវ៉ៃបែកភ្នំពេញខ្ញុំរត់ទៅរហូតទៅ ទៅនៅស្រុកថៃទៅ ។

ទ្រីៈ មីងនៅជិរំប៉ុន្មានឆ្នាំដែរ?

ខនៈ យី! យូដែរមានតិចអី ខ្ញុំចេញមកឆ្នាំ៩២ ។

ទ្រីៈ អីចឹងមីងមកពីជិរំមកនៅណោះម៉ង?

ខនៈ ចាំ! ខ្ញុំមកនៅស្រុកវិញ ។

ទ្រីៈ ម៉េចបានមីងអត់ទៅនៅស្អាងអីចឹង?

ខនៈ ខ្ញុំមកនៅស្រុកខាងប្ដីខ្ញុំហ្នឹង ។

ទ្រីៈ មីងមកដល់ជំនាន់យើងឥឡូវនេះមានដែរនឹកឃើញជំនាន់ខ្មែរក្រហមទេ?

ខនៈ ចាំ! សើច.. នឹកឃើញជំនាន់ខ្មែរក្រហមដូច...

ទ្រីៈ មានដែរនឹកឃើញទេ?

ខនៈ នឹកឃើញកាលរត់អីចឹងអីតែនឹកឃើញហើយ រត់បបេកបបាកខ្លាច ។

ទ្រីៈ រត់ពេលណាដែរ?

ខនៈ រត់វ៉ៃរំដោះចូលភ្នំពេញហ្នឹង ហីពួកខ្ញុំមិនរត់ទៅក្រៅរហូតហ្នឹង ។

ទ្រីៈ អីចឹងប្រជាជនងាប់ច្រើនមីង?

ខនៈ រត់បេះតែងាប់ហើយ អត់បាយ អត់ទឹកងាប់តាមផ្លូវអាហូតហ្នឹង ។

ទ្រីៈ អីចឹងដល់ពេលជំនាន់ខ្មែរក្រហមអត់ដែលឃើញមនុស្សស្លាប់ទេ?

ខនៈ ជំនាន់ខ្មែរក្រហមចុះនៅដូចខ្ញុំប្រាប់អីចឹងនៅគ្នាតិចៗអីចឹងណាមានដឹងស្អី អ្នកឈឺទៅពេទ្យ
ចាំអត់មាននៅចំណោមច្រើនអត់ឃើញទេ ។

ទ្រីៈ មីងកាលហ្នឹងអត់មានពុគុកទួលស្លែងពុស-២១អីទេ?

ខនៈ អត់ដែរស្គាល់សុទ្ធ គុកទួលស្លែងគុកព្រៃសរអត់ដែរទេ មិនដែលពុផង ។

ទ្រីៈ ប៉ុនដល់ពេលសម័យក្រោយមកបានមីងដឹងរឿងទួលស្លែងហ្នឹងឬ?

ខនៈ អត់ពុតែឈ្មោះប៉ុនមិនដឹងនៅឯណា ។

ទ្រី:	អីចឹងខ្ញុំអរគុណមីង!

ខន:	ចា៎!

ទ្រី:	អរគុណមីងច្រើនមែនទែនដែលខំជួយបញ្ជាក់ប្រាប់ ។